វិទ្យាស្ថានសភាកម្ពុជា

PARLIAMENTARY INSTITUTE OF CAMBODIA

## ឯកសារស្រាវជ្រាវសង្ខេប

គណៈកម្មការសុខាភិបាល សង្គម អតីតយុទ្ធជន យុវនីតិសម្បទា ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

# កម្មវិធីគាំពារសង្គមនៅក្នុងប្រទេសកម្ពុជា៖ បច្ចុប្បន្ន និងអនាគត


អ្នកនិពន្ធ៖ លោក ជីម ប៊ុនធឿន
លោក ឈន ហាំ
កញ្ញា មុំ ចិន្តា
កញ្ញា វង្ស ច័ន្ទរស្មីដារា



ខែមករា ឆ្នាំ២០១៩



ការិយាល័យរបស់វិទ្យាស្ថានសភាកម្ពុជា៖ ផ្ទះលេខ ៣២ ផ្លូវលេខ ៩ សង្កាត់ទន្លេបាសាក់ រាជធានីភ្នំពេញ
និងនៅក្នុងបរិវេណព្រឹទ្ធសភា វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
+855 (0) 23 210 055/6 | admin@pic.org.kh | www.pic.org.kh

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែរាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៨ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) ។

# មាតិការ


១. សេចក្តីផ្តើម ........ 1

២. កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមបច្ចុប្បន្ននៅកម្ពុជា ........ 1

២.១ ជំនួយសង្គម ........ 2

២.១.១ ការអភិវឌ្ឍធនធានមនុស្ស ........ 2

២.១.២ ការឆ្លើយតបនឹងគ្រោះអាសន្ន ........ 3

២.១.៣ សុខុមាលភាពសង្គមសម្រាប់មនុស្សចាស់ និងពិការភាព ........ 3

២.១.៤ ការគាំពារសុខភាពសង្គម ........ 4

២.១.៥ ឱកាសទី២ ឬការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសក្រៅផ្លូវការ(TVET) ........ 4

២.២ សន្តិសុខសង្គម (ធានារ៉ាប់រងសង្គម) ........ 4

២.២.១ ការអនុវត្តធានារ៉ាប់រងសង្គម ........ 4

២.២.២ សមិទ្ធិផលនៃការអនុវត្តការធានារ៉ាប់រងសង្គមតាមរយៈNSSF ........ 7

៣. បញ្ហា និងកត្តាប្រឈមចំពោះកម្មវិធីគាំពារសង្គមនៅកម្ពុជា ........ 9

៣.១ ប្រព័ន្ធជំនួយសង្គម ........ 9

៣.២ របបសន្តិសុខសង្គម ........ 10

៤. ការសិក្សាប្រៀបធៀបការអនុវត្ត និងការចំណាយ កម្មវិធីគាំពារសង្គម ........ 10

៤.១ ការសិក្សាប្រៀបធៀបចំពោះការអនុវត្ត ........ 10

៤-២ ការចំណាយសម្រាប់វិស័យសុខាភិបាល និងកម្មវិធីគាំពារសង្គម កម្ពុជា ថៃ បារាំង និងជប៉ុន .. 23

៥- ចំណុចពិភាក្សា ........ 23

៦- សេចក្តីសន្និដ្ឋាន ........ 25

ឯកសារយោង ........ 26

## ១. សេចក្តីផ្តើម

ការលើកកម្ពស់សុខមាលភាពសង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ គឺជាតួនាទីស្នូលរបស់រដ្ឋាភិបាល។ រដ្ឋាភិបាលភាគច្រើនបានបង្កើតកម្មវិធីរបបសន្តិសុខសង្គម ដែលផ្តល់អត្ថប្រយោជន៍សម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន ជាពិសេសជនក្រីក្រ និងជនងាយរងគ្រោះ។ កម្មវិធីទាំងនេះ បានផ្តល់មូលនិធិបន្ថែមដើម្បីគាំទ្របុគ្គល និងគ្រួសារដែលជួបប្រទះនូវបញ្ហាប្រាក់ចំណូលទាប ភាពអត់ការងារធ្វើ និងព្រឹត្តិការណ៍ជីវិតផ្សេងៗ ដូចជា៖ ជំងឺ ការចិញ្ចឹមកូន និងការចូលនិវត្តន៍។

ដោយសារកម្ពុជាបានចាកចេញពីប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានមានចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវកម្មវិធីសុខមាលភាពមួយចំនួន និងដោយសារកិច្ចប្រឹងប្រែងមួយផ្នែកនៃការអនុវត្តកម្មវិធីសុខមាលភាពសង្គម បានធ្វើឱ្យអត្រាភាពក្រីក្រធ្លាក់ចុះពី៤៧,៨% ក្នុងឆ្នាំ២០០៧ ទៅ១៣,៥% ក្នុងឆ្នាំ២០១៤ [1, 2]។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋប្រមាណ៤,៥លាននាក់ នៅតែស្ថិតនៅជិតបន្ទាត់នៃភាពក្រីក្រ និងងាយរងគ្រោះត្រឡប់ទៅក្រោមបន្ទាត់ភាពក្រីក្រវិញ ប្រសិនបើមានវិបត្តិសេដ្ឋកិច្ច ឬ វិបត្តិខាងក្រៅ[1]។

ដើម្បីដោះស្រាយបន្ថែមលើបញ្ហាប្រាក់ចំណូលទាប និងហិរញ្ញវត្ថុនៅកម្ពុជា រាជរដ្ឋាភិបាលបានអនុម័តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។ ក្របខ័ណ្ឌនេះមានសសរស្តម្ភពីរ គឺជំនួយសង្គម និងសន្តិសុខសង្គម។ ក្របខ័ណ្ឌនេះកំណត់ថាជំនួយសង្គមគឺជាការជួយដល់ជនក្រីក្រ និងអ្នកងាយ រងគ្រោះតាមរយៈថវិកាជាតិ ឬជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ខណៈដែលរបបសន្តិសុខសង្គមអន្តរាគមន៍ដើម្បីការពារប្រជាជនពីការធ្លាក់ចុះនៃប្រាក់ចំណូលភ្លាមៗ ដោយសារជំងឺដែលមិននឹកស្មានដល់ ភាពអត់ការងារធ្វើ គ្រោះថ្នាក់ការងារ មរណភាពមេគ្រួសារ មាតុភាព និងអាយុចាស់ជរា[3]។

ឯកសារសង្ខេបនេះនឹងផ្តល់ទិដ្ឋភាពទូទៅ នៃកម្មវិធីគាំពារសង្គមនាពេលបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា (ទាំងជំនួយសង្គម និងរបបសន្តិសុខសង្គម)។ ឯកសារនេះក៏នឹងពិនិត្យមើលផងដែរ អំពីបញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីគាំពារសង្គម ហើយនឹងផ្តល់ការប្រៀបធៀបជាមួយកម្មវិធីជំនួយសង្គម និងសន្តិសុខសង្គម នៅប្រទេសថៃ ជប៉ុន និងបារាំង។

## ២. កម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គមបច្ចុប្បន្ននៅកម្ពុជា

ផ្នែកនេះនឹងពិនិត្យមើលនូវវឌ្ឍនភាពពាក់ព័ន្ធនឹងកម្មវិធីទាំងពីរខាងលើនេះ គឺកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម។ សូមពិនិត្យមើលសេចក្តីសង្ខេប នៃកម្មវិធីគាំពារសង្គមនៅក្រោមប្រភេទនៃកម្មវិធីនីមួយៗនៅក្នុងតារាង ២.១ ខាងក្រោម៖

**តារាង២.១ សង្ខេប នៃកម្មវិធីនៅក្រោមប្រភេទនីមួយៗ**

| ជំនួយសង្គម | ធានារ៉ាប់រងសង្គម |
| --- | --- |
| • ការអភិវឌ្ឍធនធានមនុស្ស<br>• ការឆ្លើយតបនឹងគ្រោះអាសន្ន<br>• សុខុមាលភាពសង្គមសម្រាប់មនុស្សចាស់និងពិការភាព<br>• ការគាំពារសុខភាពសង្គម(មូនិធិសមធម៌)<br>• ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស | • ប្រាក់សោធននិវត្តន៍<br>• ធានារ៉ាប់រងសុខភាព<br>• គ្រោះថ្នាក់ការងារ |

## ២.១ ជំនួយសង្គម

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តនូវកម្មវិធីជំនួយសង្គមជាងមួយទសវត្សមកហើយ។ កម្មវិធីនេះត្រូវបានអនុវត្តដោយក្រសួងផ្សេងៗគ្នាដូចជា៖ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) ក្រសួងសុខាភិបាល (MoH) គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាមួយដៃគូរអភិវឌ្ឍន៍ផ្សេងៗទៀត រួមមាន៖ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី កម្មវិធីស្បៀងអាហារពិភពលោក UNICEF និង USAID[4]។ ឆ្លងតាមការអនុវត្តកន្លងមក កម្មវិធីជំនួយសង្គមនៅកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ជាខ្លាំងលើការអភិវឌ្ឍធនធានមនុស្ស និងការឆ្លើយតបនឹងគ្រោះអាសន្ន[5]។ កម្មវិធីតូចៗមួយចំនួនផ្សេងទៀតក៏មានផងដែរ។

### ២.១.១ ការអភិវឌ្ឍធនធានមនុស្ស

សម្រាប់ការអភិវឌ្ឍធនធានមនុស្ស រាជរដ្ឋាភិបាលកម្ពុជាដែលបានអនុវត្តកម្មវិធី គាំពារស្ត្រីមានផ្ទៃពោះ និងកុមារ ការផ្តល់អាហារបំប៉ននៅតាមសាលារៀន និងកម្មវិធីអាហារូបករណ៍។ រហូតមកដល់ពេលនេះ កុមារនៅសាលារៀនប្រមាណ ៣00 000 នាក់ នៅក្នុងខេត្តចំនួន ៩ កំពុងអនុវត្តកម្មវិធីផ្តល់អាហារបំប៉នតាមសាលារៀនដោយសហការជាមួយអង្គការកម្មវិធីស្បៀងអាហារពិភពលោក ដើម្បីផ្តល់អាហារពេលព្រឹកដល់កុមារនៅសាលារៀន[3]។ លើសពីនេះទៀត សិស្សថ្នាក់ទី ៤-៦ ចំនួន ៧៥ 000នាក់ កំពុងទទួលបាន អាហារូបករណ៍ប្រហែល ៦0ដុល្លារក្នុងមួយឆ្នាំ ពីក្រសួងអប់រំ យុវជន និងកីឡា ខណៈសិស្សចំនួន ២៥ 000 នាក់កំពុងទទួលបានអាហារូបករណ៍ ពីអង្គការកម្មវិធីស្បៀងអាហារពិភពលោក[3]។

ក្រសួង អប់រំ យុវជន និងកីឡា ក៏បានផ្តល់អាហារូបករណ៍ដល់សិស្សានុសិស្សនៅតាមសាលាមធ្យមសិក្សា ដើម្បីលើកទឹកចិត្តយុវជនឱ្យបន្តការសិក្សា។ កម្មវិធីផ្តល់អាហារបំប៉ន និងអាហារូបករណ៍របស់សាលារៀនត្រូវបានអនុវត្តនៅក្នុងតំបន់ដែលមានបញ្ហាអសន្តិសុខស្បៀង និងការទទួលបានការអប់រំទាប។

### ២.១.២ ការឆ្លើយតបនឹងគ្រោះអាសន្ន

នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគម្រោងជំនួយស្បៀងគ្រោះអាសន្ន(EFAP) ដើម្បីជួយប្រជាជនក្រីក្រប្រហែល៥០០ ០០០នាក់ ដែលរងគ្រោះដោយសារតម្លៃទំនិញខ្ពស់ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍តាមរយៈកម្ចី និងជំនួយឥតសំណង។ EFAP បានបញ្ចប់នៅឆ្នាំ ២០១៥ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកកម្មវិធីនេះ ទៅក្នុងទម្រង់នៃកម្មវិធីពីរគឺ ប្រាក់សម្រាប់ការងារ និងស្បៀងសម្រាប់ការងារ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតមូលនិធិគ្រាអាសន្នលើមូលដ្ឋានចំពោះកិច្ចដោយវិភាជន៍មូលនិធិនេះទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីជួយជនរងគ្រោះពីគ្រោះមហន្តរាយធម្មជាតិ និងគ្រាអាសន្នផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ មូលនិធិនេះ ពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រភពខាងក្រៅ។

### ២.១.៣ សុខុមាលភាពសង្គមសម្រាប់មនុស្សចាស់ និងពិការភាព

រាជរដ្ឋាភិបាល បន្តកម្មវិធីជំនួយសង្គមបន្ថែមទៀតសម្រាប់គាំទ្រក្រុមងាយរងគ្រោះរួមមាន សុខុមាលភាពសង្គមសម្រាប់មនុស្សចាស់ សុខុមាលភាពសង្គមសម្រាប់ជនពិការ ប្រាក់ឧបត្ថម្ភសម្រាប់ជនពិការ និងសុខុមាលភាពសង្គមសម្រាប់កុមារងាយរងគ្រោះ និងកុមារកំព្រា។ សូមមើលបន្ថែមនៅក្នុងតារាង ២.២ ។

**តារាង២.២ កម្មវិធី/គម្រោងជំនួយសង្គមសម្រាប់ក្រុមងាយរងគ្រោះ**

| កម្មវិធី/គម្រោង | ប្រភេទ និងតម្លៃនៃការផ្ទេរ | អ្នកដែលត្រូវទទួលបាន | គ្របដណ្តប់ | ក្រសួង/ភ្នាក់ងារ |
|---|---|---|---|---|
| សុខុមាលភាពសង្គមសម្រាប់មនុស្សចាស់ | - | មនុស្សចាស់ (អាយុ ៦៥ ឆ្នាំឡើង) | ខេត្ត៖ ១១ | MoSVY |
| សុខុមាលភាពសង្គមសម្រាប់គ្រួសារដែលមានពិការភាព | - | ជនពិការដែលក្រីក្រ ចាស់ជរា ឬគ្មានការឧបត្ថម្ភពីគ្រួសារ | អ្នកទទួលផល៖ 300 000 នាក់ (ជិត១00%) | MoSVY |
| ប្រាក់ឧបត្ថម្ភសម្រាប់ពិការភាព | សាច់ប្រាក់៥ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ | ជនពិការដែលក្រីក្រចាស់ជរា ឬគ្មានការឧបត្ថម្ភពីគ្រួសារ ផ្ទៀងផ្ទាត់ដោយអាជ្ញាធរមូលដ្ឋាន | ទូទាំងប្រទេស | MoSVY |
| សុខុមាលភាពសង្គមសម្រាប់កុមារងាយរងគ្រោះនិងក្មេងកំព្រា | សេវាសង្គម និង ១,២៥ ដុល្លារ | កុមារងាយរងគ្រោះនិងកុមាររស់នៅក្នុងមណ្ឌលថែទាំ | ទូទាំងប្រទេស<br>-មណ្ឌល៖ ២៥៣<br>-កុមារ៖ ១១ ០១៧ | MoSVY/ NGOs |

| | | | | |
|---|---|---|---|---|
| | សហរដ្ឋអាមេរិក ក្នុង ១ថ្ងៃ/ក្មេង១នាក់ | | (ទទួលខុសត្រូវ ដោយរាជរដ្ឋាភិបាលកម្ពុជា) | |

*ប្រភព: [5]*

### ២.១.៤ ការគាំពារសុខភាពសង្គម

រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាលបានបង្កើតមូលនិធិសមធម៌ (HEF) ដើម្បីផ្តល់ការឧបត្ថម្ភធនថ្លៃសេវាថែទាំសុខាភាពដល់ប្រជាពលរដ្ឋដែលមានចំណូលទាបដែលកាន់ប័ណ្ណក្រីក្រ។[1] មូលនិធិសមធម៌ប្រើប្រាស់សម្រាប់៖ ការបង់ថ្លៃសេវា សកម្មភាពអប្បបរមានៅមណ្ឌលសុខភាព នីតិវិធីសម្រាប់ស្រ្តីមានផ្ទៃពោះដើម្បីទៅមន្ទីរពេទ្យ ការអនុញ្ញាត្តិឱ្យទៅមន្ទីរពេទ្យ ការគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងអំឡុងពេលស្នាក់នៅមន្ទីរពេទ្យ និងការធ្វើដំណើរ។ បច្ចុប្បន្នកម្មវិធីនេះ ផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រហែល ៣ លាននាក់ដែលមានចំនួន ៩២.៧% នៃប្រជាជនក្រីក្រសរុប[6]។

### ២.១.៥ ឱកាសទី២ ឬការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសក្រៅផ្លូវការ(TVET)

គោលបំណងនៃគម្រោងនេះ គឺ ដើម្បីជួយយុវជនដែលបោះបង់ការសិក្សាពីគ្រួសារក្រីក្រដែលត្រូវបានកំណត់អត្តសញ្ញាណដោយសាលារៀន និងអាជ្ញាធរមូលដ្ឋាន។ តាមរយៈគម្រោងនេះ (អនុវត្តដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) សិស្សបោះបង់ការសិក្សាអាចទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសដែលការចំណាយសម្រាប់ការបណ្តុះបណ្តាលមានតម្លៃចំនួន ២៨ ដុល្លារក្នុងមួយសប្តាហ៍ និង ១00ដុល្លារ សម្រាប់រយៈពេលមួយឆ្នាំ ដែលចំណាយនេះជាបន្ទុករដ្ឋាភិបាល[5]។ ចាប់ពីឆ្នាំសិក្សា ២00៩-២០១៣ សិស្សចំនួន ៦00 000នាក់ បានបញ្ចប់ការសិក្សាពី៖ ១. ជំនាញជាន់ខ្ពស់ និងមូលដ្ឋាន ២. បច្ចេកទេសក្រោយប្រមូលផល ៣. ការបំពេញជំនាញដែលខ្វះខាត ៤. ការបណ្តុះបណ្តាលជាក់លាក់សម្រាប់ក្រុមជនជាតិភាគតិច ៥. កម្មវិធីកាត់បន្ថយភាពក្រីក្រ ៦) ភាពជាសហគ្រិន និង ៧. ការហ្វឹកហាត់ការងារ [3]។

## ២.២ សន្តិសុខសង្គម (ធានារ៉ាប់រងសង្គម)

### ២.២.១ ការអនុវត្តធានារ៉ាប់រងសង្គម

ប្រទេសកម្ពុជាមានប្រព័ន្ធធានារ៉ាប់រងសង្គមសម្រាប់ ២ ក្រុម៖ គឺមួយសម្រាប់បុគ្គលិកផ្នែកឯកជន និងមួយទៀតសម្រាប់បុគ្គលិកផ្នែកសាធារណៈ។ ការធានារ៉ាប់រងសង្គមត្រូវបានគ្រប់គ្រងតាមរយៈមូលនិធិសន្តិសុខសង្គមជាតិ (NSSF) និងក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា(MoSVY) ។ ខណៈពេលដែល NSSF គ្រប់គ្រងការធានារ៉ាប់រងសង្គមសំរាប់បុគ្គលិកឯកជន ក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា គ្រប់គ្រងការធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការ នគរបាល ទាហាន និងអតីតយុទ្

[1] គឺជាកាតដែលផ្តល់ដោយដើម្បីបញ្ជាក់ថាអ្នកដែលកាន់កាតនេះអាចទទួលបាននូវសេវាពិសេស

ជនតាមរយៈមូលនិធិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល (NSSF-C) និងមូលនិធិជាតិសម្រាប់អតីតយុទ្ធជន (NFV) ។

សមាសធាតុសំខាន់ៗបី នៃការធានារ៉ាប់រងសង្គមដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលកម្ពុជា គឺប្រាក់សោធននិវត្តន៍ ការធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារ។ តារាងខាងក្រោម ២.២ ឆ្លុះបញ្ចាំងពីការ អនុវត្តនៃគម្រោងនីមួយៗ និងកម្មវិធីដទៃទៀត ដែលអនុវត្តដោយ NSSF និង MoSVY ។

**តារាង ២.២ របបសន្តិសុខសង្គមតាមវិស័យ**

| គម្រោង | វិស័យឯកជន | វិស័យសាធារណៈ |
|---|---|---|
| ប្រាក់សោធននិវត្តន៍ | ប្រាក់សោធននិវត្តន៍សំរាប់និយោជិតឯកជនត្រូវបានចែងនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលត្រូវបានកំណត់ដោយច្បាប់ការងារចាប់ឆ្នាំ ២០០២ ប៉ុន្តែការអនុវត្តមិនទាន់បានចាប់ផ្តើមនៅឡើយទេ។ ទោះជាយ៉ាងណា រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្តនៅគម្រោងនេះឆ្នាំ២០១៩ បើយោងតាមសេចក្តីថ្លែងហេតុនៃច្បាប់ថវិកាជាតិឆ្នាំ ២០១៩ ។ | ប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីសាធារណៈ គឺប្រហែល ៦០% -៨0% នៃប្រាក់ខែគោល (មិនរាប់បញ្ចូលប្រាក់មុខតំណែងឡើយ)។ វាអាស្រ័យលើការឧបត្ថម្ភពីរដ្ឋាភិបាល [3, p.22] ។ បច្ចុប្បន្ននេះមន្ត្រីរាជការសាធារណៈ ប៉ូលីស និងទាហានដែលចូលនិវត្តន៍ទទួលបានអត្ថប្រយោជន៍ចូលនិវត្តន៍មានតែ ៧% ប៉ុណ្ណោះនៃចំនួនប្រជាជនសរុប។ រដ្ឋាភិបាលគ្រោងនឹងចំណាយប្រហែល ៦០ ៣ន់ លានរៀល លើប្រាក់សោធននិវត្តន៍របស់មន្ត្រីរាជការសាធារណៈក្នុងឆ្នាំ ២០១៩ [7, p.20]។ គម្រោងនេះបានគ្របដណ្តប់ប្រហែល ១៨0 000 មន្ត្រីរាជការ ៨៧ ៥០០ អតីតយុទ្ធជន ប៉ូលីស ទាហាន និងអ្នកនៅក្នុងបន្ទុករបស់ពួកគេ។ |
| ធានារ៉ាប់រងសុខភាព | និយោជិតមួយចំនួននៅក្នុងវិស័យឯកជនទទួលបានការធានារ៉ាប់រងសុខភាពដោយផ្ទាល់ពីក្រុមហ៊ុនរបស់ពួកគេ។ ទោះបីជាយ៉ាងណាក៏ដោយយោងទៅតាមរបាយការណ៍របស់រដ្ឋាភិបាលមានតែក្រុមហ៊ុនធានារ៉ាប់រងឯកជនចំនួន៨ តែប៉ុណ្ណោះ | ការធានារ៉ាប់រងសុខភាពសម្រាប់បុគ្គលិកសាធារណៈចាប់ផ្តើមនៅឆ្នាំ ២០១៨ ដោយផ្អែកលើព្រះរាជក្រឹត្យលេខ ០២១១៧/០៧៨ ចុះថ្ងៃទី ០១ ខែកុម្ភៈឆ្នាំ ២០១៧ នឹងចូលជាធរមានក្នុងឆ្នាំ ២០១៨។ នៅឆ្នាំ |

| | | | |
|---|---|---|---|
| | | បម្រើនៅប្រទេសកម្ពុជាដោយមានដើមទុនប្រមាណ៩,២លានដុល្លារ។ ពួកគេគ្របដណ្ដប់តែចំណែកតូចមួយនៃការងារសរុបនៅក្នុងវិស័យឯកជនប៉ុណ្ណោះ។ នៅក្រោមគ្រោងនេះនិយោជកត្រូវបង់ប្រាក់ធានារ៉ាប់រងសុខភាពដល់ NSSF សម្រាប់និយោជិតក្នុងអត្រា ១,៣% នៃប្រាក់ឈ្នួលសរុបដែលបានកំណត់ដោយ NSSF ហើយបុគ្គលិកខ្លួនឯងត្រូវរួមវិភាគទានចំនួន ១.៣% ផងដែរ[8] ។ | ២០១៩ រដ្ឋាភិបាលមានគម្រោងបង្កើនការចំណាយលើការធានារ៉ាប់រងសុខភាពសម្រាប់មន្ត្រីសាធារណៈប្រហែល ៥0 ពាន់លានរៀល [7, p.20]។ |
| គ្រោះថ្នាក់ការងារ | | ស្ថាប័នឯកជនដែលមានបុគ្គលិកយ៉ាងតិចប្រាំបីនាក់ត្រូវតែចុះឈ្មោះសម្រាប់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារនៅ NSSF តាមច្បាប់ស្តីពី របបសន្តិសុខសង្គមសម្រាប់អ្នកដែលកំណត់ដោយច្បាប់ការងារឆ្នាំ ២00២។ និយោជកត្រូវបង់ប្រាក់ធានារ៉ាប់រងនេះសម្រាប់និយោជកក្នុងអត្រា 0,៨% នៃប្រាក់ឈ្នួលសរុបជាមធ្យមកំណត់ដោយ NSSF [8]។ ប្រសិនបើនិយោជិតបាត់បង់សមត្ថភាពក្នុងការធ្វើការជាអចិន្ត្រៃយ៍ដោយសារតែគ្រោះថ្នាក់ការងារ គាត់នឹងទទួលបានប្រាក់ឈ្នួលសរុប និងអត្ថប្រយោជន៍ផ្សេងទៀត។ | យោងតាមអនុក្រឹត្យលេខ ១៣៤ ចេញថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៧ ស្តីពីលក្ខខ័ណ្ឌបែបបទ និងនីតិវិធីនៃការផ្តល់អត្ថប្រយោជន៍នៃគម្រោងសន្តិសុខសង្គមស្តីពីគ្រោះថ្នាក់ការងារសម្រាប់មន្ត្រីសាធារណៈ និងការថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ ការអនុវត្តនេះនឹងចូលជាធរមានចាប់ពីឆ្នាំ ២០១៩។ ឥឡូវនេះ ការធានារ៉ាប់រងក្រោមគម្រោងនេះត្រូវបានអនុវត្តខុសៗគ្នាតាមក្រសួងពាក់ព័ន្ធ។ រដ្ឋាភិបាលគ្រោងនឹងចំណាយលើគម្រោងធានារ៉ាប់រងគ្រោះថ្នាក់ការងារប្រមាណ ៦ ពាន់លានរៀលសម្រាប់បុគ្គលិកសាធារណៈដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាល [7, p.20]។ |
| **ផ្សេងៗ** | **មាតុភាព** | ស្ត្រីដែលសម្រាលកូនម្នាក់នឹងទទួលបានប្រាក់ ៤00 000 រៀលកូនពីរនាក់ចំនួន ៨00 000 រៀល និងកូនបីនាក់ ១ ២00 000 រៀលដោយផ្អែកតាម | ចំពោះការងារសាធារណៈស្ត្រីដែលផ្តល់កំណើតកូនម្នាក់ នឹងទទួលបាន ៨00 000 រៀលដោយផ្អែកលើអនុក្រឹត្យលេខ ១៩៤ ចុះថ្ងៃទី ២0 ខែវិច្ឆិកាឆ្នាំ ២០១៧។ |

| | | | |
|---|---|---|---|
| | | ប្រកាសលេខ ៤០៤ ចុះថ្ងៃទី ១១ ខែតុលាឆ្នាំ ២០១៧។ | |
| | **សេចក្ដីស្លាប់** | យោងតាមមាត្រា ១០ នៃច្បាប់ស្ដីពីរបបសន្តិសុខសង្គមសម្រាប់បុគ្គលដែលបានកំណត់ដោយច្បាប់ការងារ, សមាជិក NSSF ណាដែលបានបង់រយៈពេល ១៨០ខែ ដែលបានបង់របបសន្តិសុខសង្គម គ្រួសាររបស់អ្នកទទួលមរណភាព និងត្រូវទទួលបានប្រាក់សោធននិវត្តន៍។ | ដោយផ្អែកលើមាត្រា ៥ នៃអនុក្រឹត្យលេខ ១៩៤ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៧ ប្រសិនបើមន្ត្រីរាជការទទួលមរណភាពក្នុងអំឡុងពេលបំពេញបេសកកម្មនោះគាត់នឹងទទួលបានប្រាក់ឧបត្ថម្ភពី ១ ៥០០ ០០០ រៀលដល់ ៤ ០០០ ០០០ រៀលសម្រាប់បុណ្យសព និងប្រាក់ឧបត្ថម្ភចំនួនប្រាំមួយខែនៃប្រាក់ខែចុងក្រោយសរុប រួមទាំងប្រាក់សោធនជនរងគ្រោះត្រូវបង់ទៅឱ្យស្ត្រីមេម៉ាយ និងកូនៗ ។ |
| | **ប្រាក់រង្វាន់អត្ថប្រយោជន៍** | ត្រូវបានផ្ដល់ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃចំនួន ៧០% របស់សាម៉ីជន កំឡុងពេលមានជំងឺ គ្រោះថ្នាក់ការងារ សំរាកលំហែមាតុភាព ឬគ្រោះថ្នាក់ផ្សេងទៀត | ប្រាក់បៀវត្សរ៍ទាំងអស់ រួមទាំងប្រាក់ឧបត្ថម្ភសម្រាប់រយៈពេលបីខែជាប់ៗគ្នានៃជំងឺ និង ៩០% នៃប្រាក់ខែរហូតដល់ ១២ ខែ អាស្រ័យចំនួនឆ្នាំនៃការបម្រើការងារ។ |

***ប្រភព៖*** *ក្របខ័ណ្ឌគោលនយោបាយគាំពារសង្គម ២០១៦-២០២៥ និងរបាយការណ៍សមិទ្ធផល ១០ ឆ្នាំ (២០០៨-២០១៧) និងទស្សនៈវិស័យឆ្នាំ២០១៨ និង OECD, 2017[3, 5, 9]*

### ២.២.២ សមិទ្ធិផលនៃការអនុវត្តការធានារ៉ាប់រងសង្គមតាមរយៈNSSF

- **គ្រោះថ្នាក់ការងារពីឆ្នាំ២០០៩-២០១៧**

ចំនួនសហគ្រាសដែលបានចុះបញ្ជីសម្រាប់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារបានកើនឡើងពី ៩៨៣នាក់ទៅ ១០ ៨៥៩ នាក់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៧។ ចំនួននៃនិយោជិត ដែលគ្របដណ្ដប់ដោយកម្មវិធីនេះបានកើនឡើងពី ៤៥១ ២៣២ នាក់ទៅ ១ ៤៣៥ ៣១៦ នាក់ក្នុងរយៈពេលដូចគ្នា។ ចំនួនសហគ្រាសដែលបង់សម្រាប់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារមានរវាង ៨២%-៩៣% នៃសហគ្រាសដែលបានចុះបញ្ជីសរុប[9, p.5]។ រូបភាព ២.១ ខាងក្រោមបង្ហាញពីការបង់វិភាគទានធានារ៉ាប់រងគ្រោះថ្នាក់ការងារដោយនិយោជកបានកើនឡើងពី ៨ពាន់លានរៀល ក្នុងឆ្នាំ ២០០៩ ដល់ ៩២ ពាន់លានរៀលនៅឆ្នាំ ២០១៧ ខណៈពេលដែលចំនួនសមាជិកដែលបានទូទាត់មកវិញពីប្រាក់ធានារ៉ាប់រងប្រភេទនេះក៏កើនឡើងដែរ។ ការចំណាយសម្រាប់គ្រោះថ្នាក់ការងារពីឆ្នាំ២០០៩-២០១៧ មានចំនួន ៣,៧% ជាមធ្យម នៃវិភាគទានសរុប និងចំនួនសមាជិកដែលទូទាត់មកប្រាក់ធានារ៉ាប់រងគ្រោះថ្នាក់ការងារមកវិញមានប្រមាណចំនួន២,១% ជាមធ្យមនៃចំនួនសមាជិកសរុបទាំងអស់។

**រូបភាពទី ២.១៖ វិភាគទានសម្រាប់ធានារ៉ាប់រងគ្រោះថ្នាក់ការងារ ប្រាក់ចំណូល និងសមាជិកបានទូទាត់មកវិញពីការធានារ៉ាប់រងគ្រោះថ្នាក់ការងារ(២០០៩-២០១៧)**




***ប្រភព៖** របាយការណ៍ស្តីពីសមិទ្ធផលរយៈពេល ១០ ឆ្នាំ (២០០៨-២០១៧) និងទស្សនៈវិស័យឆ្នាំ២០១៨[១]*

រូបភាព ២.១ បង្ហាញថា មូលនិធិសម្រាប់ការធានារ៉ាប់រងគ្រោះថ្នាក់ការងារមានស្ថិរភាព ដោយសារការចំណាយលើការធានារ៉ាប់រងនេះ មានត្រឹមតែ ៣,៧% ជាមធ្យម ក្នុងមួយឆ្នាំក្នុងទសវត្សចុងក្រោយនេះ ដូច្នេះរដ្ឋាភិបាលអាចពិចារណាដើម្បីបង្កើនអត្ថប្រយោជន៍បន្ថែមទៀតពីប្រភេទនៃការធានារ៉ាប់រងនេះ។

- **ធានារ៉ាប់រងសុខភាពពីឆ្នាំ ២០១៦-២០១៧**

យោងទៅតាមរបាយការណ៍របស់ ប.ស.ស នៅក្នុងឆ្នាំ២០១៧ ប.ស.សបានធ្វើអត្តសញ្ញាណកម្មចំនួនសហគ្រាសបានចំនួន៣ ២៧១ សហគ្រាស (៣៨,៤៥% នៃសហគ្រាសសរុបដែលបានចុះបញ្ជី)។ ទោះជាយ៉ាងណាក៏ដោយ សហគ្រាសចំនួនត្រឹមតែ ៦២៦ (១៩% នៃសហគ្រាសដែលបានធ្វើអត្តសញ្ញាណកម្មឡើងវិញ) ដែលត្រូវបានកំណត់ឱ្យជាប់វិភាគទានក្នុងការបង់ធានារ៉ាប់រងសុខភាព ហើយសហគ្រាសចំនួនត្រឹមតែ ៦១០ ដែលបានបង់វិភាគទាននៅក្នុងឆ្នាំ ២០១៧ គ្រប់ដណ្តប់កម្មករចំនួន ៦០៨ ៩៦៥ (៥០៥ ៦០៥ ជាស្ត្រី) ដែលមានវិភាគទានចំនួនប្រមាណ១៥ ៤៧៥ ពាន់លានរៀល។ បន្ថែមពីលើនេះ ប.ស.ស បានចុះកិច្ចព្រមព្រៀងជាមួយភ្នាក់ងារសុខភាពចំនួន ១ ២៩៥កន្លែង រួមមានមន្ទីរពេទ្យជាតិចំនួន ០៤ មណ្ឌលសុខភាពចំនួន១០៧ កន្លែង និងមន្ទីរពេទ្យឯកជនចំនួន ១៥កន្លែង។ ជាលទ្ធផល សមាជិកចំនួន ២១៨ ៦៩៧នាក់ បានទូទាត់មកវិញលើធានារ៉ាប់រងសុខភាពពីប.ស.ស ក្នុងឆ្នាំ ២០១៧[១]។ គួរបញ្ជាក់ផងដែរថា ប.ស.ស បានចំណាយលើសេវាធានារ៉ាប់រងសុខភាពចំនួន ២៧,៤ ពាន់លានរៀលចាប់ពីឆ្នាំ២០១៦-២០១៧។ រូបភាពទី២.១ខាងលើបានបង្ហាញថា រដ្ឋាភិបាលអាចមាន

វិធានការបន្ថែមទៀតក្នុងការជំរុញសហគ្រាសចុះបញ្ជីទទួលសេវាធានារ៉ាប់រងសុខភាព ដើម្បីអាចឱ្យដល់កម្មករនិយោជិតអាចទទួលបានអត្ថប្រយោជន៍សុខភាពពីគម្រោងធានារ៉ាប់រងសុខភាព។

## ៣. បញ្ហា និងកត្តាប្រឈមចំពោះកម្មវិធីគាំពារសង្គមនៅកម្ពុជា

ផ្នែកទី២ នៃអត្ថបទស្រាវជ្រាវសង្ខេបនេះបានបង្ហាញពីការខិតខំយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលដើម្បីបង្កើនគុណភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការដាក់ចេញនូវកម្មវិធី ឬគម្រោងគាំពារសង្គមជាច្រើន ទោះបីជាយ៉ាងណាក៏ដោយការអនុវត្តកម្មវិធី ឬគម្រោងទាំងនោះជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចទៅ៖

### ៣.១ ប្រព័ន្ធជំនួយសង្គម

បញ្ហាទី១ ពាក់ព័ន្ធទៅនឹងការឆ្លើយតបទៅនឹងគ្រោះអាសន្ន៖ ការសម្របសម្រួលរវាងជំនួយមនុស្សធម៌ និងប្រព័ន្ធជំនួយសង្គមមិនសូវមានប្រសិទ្ធភាពក្នុងការកំណត់អត្តសញ្ញាណក្រុមជនងាយរងគ្រោះបំផុតក្នុងពេលមានវិបត្តិធ្ងន់ធ្ងរ។

ទី២ ទោះបីជារាជរដ្ឋាភិបាលខិតខំប្រឹងប្រែងលើកកម្ពស់ការគាំពារសុខភាពដល់ប្រជាពលរដ្ឋយ៉ាងណាក្តី ក៏ការផ្គត់ផ្គង់អាហារូបត្ថមដែលមានជីវជាតិសម្រាប់កុមារ និងស្ត្រីមានផ្ទៃពោះនៅមិនទាន់មានភាពល្អប្រសើរគួរឱ្យកត់សម្គាល់ឡើយ[3]។ បើធៀបពីឆ្នាំ២០១០ និងឆ្នាំ២០១៤ កុមារអាយុក្រោម ៥ឆ្នាំ ដែលមានជំងឺក្រិនមានចំនួន ៤០% ថយមកនៅត្រឹម ៣២% និងក្មេងអាយុក្រោម ៥ឆ្នាំដែលមិនគ្រប់គីឡូថយចុះពី២៨% មកនៅត្រឹម ២៤% រីឯកុមារអាយុក្រោម ៥ឆ្នាំដែលមានជម្ងឺស្លេកស្លាំងថយចុះត្រឹមតែ ៥៦% មក៥៥% ចំណែកស្ត្រីដែលកំពុងស្ថិតនៅក្នុងវ័យបន្តពូជ (អាយុ១៥-៤៩ឆ្នាំ) មានជម្ងឺស្លេកស្លាំងកើនឡើងពី ៤៤% នៅក្នុងឆ្នាំ២០១០ ដល់ ៤៥%នៅក្នុងឆ្នាំ២០១៤ និងស្ត្រីដែលស្ថិតនៅក្នុងវ័យបន្តពូជ (អាយុពី ១៥-៤៩ឆ្នាំ) ស្គមស្គាំងមានចំនួន ១៩% ក្នុងឆ្នាំ២០១០ និង១៤% ក្នុងឆ្នាំ២០១៤[10]។

ទី៣ កម្មវិធីផ្តល់អាហារបំប៉ននៅតាមសាលារៀនពឹងផ្អែកលើជំនួយពីដៃគូអភិវឌ្ឍន៍ រីឯកម្មវិធីផ្តល់អាហាររូបករណ៍សម្រាប់សិស្សនៅមិនទាន់ទូលំទូលាយនៅឡើយទេ។ កម្មវិធីផ្តល់អាហាររូបករណ៍នេះផ្តល់ឲ្យតែសិស្សរៀនថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ប៉ុណ្ណោះ នៅមានសិស្សជាង ៥០ ០០០នាក់ទៀតដែលកំពុងរៀនថ្នាក់ទី៤ ដល់ថ្នាក់ទី៦ ដែលមិនទាន់ទទួលបានអាហាររូបករណ៍ ហើយកម្មវិធីគួរតែពង្រីកបន្ថែមទៀត[3]។

ទី៤ ការសិក្សាមានកម្រិតទាបនៅតែជាបញ្ហាចម្បងចំពោះយុវជនដែលចូលទៅក្នុងទីផ្សារការងារ។ ការបញ្ចប់សាលាមធ្យមសិក្សាត្រឹមអនុវិទ្យាល័យ គឺជាមូលដ្ឋានគ្រឹះសម្រាប់យុវជនដើម្បីទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដាក់លាក់បន្ថែមទៀត ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ[2]។

### ៣.២ របបសន្តិសុខសង្គម

ទី១ ការគ្រប់គ្រងកម្មវិធីរបបសន្តិសុខសង្គមស្ថិតនៅក្រោមក្រសួងខុសៗគ្នា និងពុំមានភាពស៊ីសង្វាក់គ្នាធ្វើអោយមានគម្លាត និងភាពត្រួតគ្នានៅក្នុងការអនុវត្តគោលនយោបាយ ដែលនាំអោយមានផលប៉ះពាល់ជាអវិជ្ជមានចំពោះប្រសិទ្ធិភាព និងស័ក្តិសិទ្ធភាពក្នុងការប្រើប្រាស់ធនធាន[4, 5]។ ឧទាហរណ៍ របបសោធននិវត្តន៍សម្រាប់មន្ត្រីរាជការស៊ីវិល ប៉ូលីស និងទាហានពុំមានភាពស៊ីសង្វាក់គ្នា ដោយសារតែមានលិខិតបទដ្ឋានគតិយុត្តិដាច់ដោយឡែកគ្រប់គ្រងរបបសោធននិវត្តន៍សម្រាប់មន្ត្រីរាជការទាំងបីប្រភេទ ហើយបញ្ហានេះនាំអោយមានការថ្នាំងថ្នាក់ចិត្តចំពោះមន្ត្រី ដែលមានឋានន្តរសក្តិដូចគ្នាប៉ុន្តែទទួលបានរបបសោធននិវត្តន៍ខុសគ្នា[2]។

ទី២ ទោះបីជាយ៉ាងណាក៏ដោយ ការចំណាយរបស់រដ្ឋលើកម្មវិធីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងមន្ត្រីចូលនិវត្តន៍ពឹងផ្អែកលើចំណូលសារពើពន្ធពីរដ្ឋាភិបាល ជាជាងការចូលរួមចំណែកពីមន្ត្រីរាជការ[6]។

សហគ្រាសជាច្រើនមិនទាន់បានចុះបញ្ជីទទួលសេវាធានារ៉ាប់រងសុខភាព សម្រាប់កម្មករនិយោជិកនៅឡើយទេ ហេតុនេះកម្មករនិយោជិតមួយចំនួនមិនអាចទទួលបានសេវាធានារ៉ាប់រងសុខភាពទេ ដែលជាហេតុនាំអោយប៉ះពាល់ដល់សុខមាលភាពរបស់កម្មករនិយោជិកតជាពិសេសអ្នកដែលទទួលបានប្រាក់ខែទាប។

## ៤. ការសិក្សាប្រៀបធៀបការអនុវត្ត និងការចំណាយ កម្មវិធីគាំពារសង្គម

### ៤.១ ការសិក្សាប្រៀបធៀបចំពោះការអនុវត្ត

នៅក្នុងផ្នែកនេះ ឯកសារស្រាវជ្រាវសង្ខេបនឹងបង្ហាញពីរបៀបដែលប្រទេសថៃ ប្រទេសបារាំង និងប្រទេសជប៉ុនអនុវត្តកម្មវិធីរបបសន្តិសុខសង្គម។ ដំបូងកិច្ចការស្រាវជ្រាវនេះនឹងរំលេចនូវការប្រៀបធៀបការអនុវត្តរវាងប្រទេសទាំងបីគឺ ប្រទេសថៃ បារាំង និងជប៉ុន។ មូលហេតុដែលយើងជ្រើសរើសយកប្រទេសទាំងបីយកមកធ្វើការសិក្សាដោយសារតែៈ ប្រទេសថៃជាប្រទេសជិតខាងកម្ពុជា និងជាប្រទេសមួយដែលមានស្ថានភាពប្រហាក់ប្រហែលនឹងកម្ពុជា ដូចនេះវាគួរតែជាប្រទេសមួយដែលអាចយកមកសិក្សាប្រៀបធៀបជាមួយកម្ពុជាពីការអនុវត្តកម្មវិធីសន្តិសុខសង្គម។ ចំណែកឯប្រទេសបារាំង និងជប៉ុន គឺជាប្រទេសអភិវឌ្ឍន៍ដែលមានបទពិសោធន៍យូរយារទាក់ទងនឹងការផ្តល់របបសន្តិសុខសង្គមជូនប្រជាពលរដ្ឋ ដែលកម្ពុជាអាចរៀនសូត្របាន។ កម្មវិធីចំនួនប្រាំនឹងលើកយកមកសិក្សាប្រៀបធៀបការអនុវត្តរបបសន្តិសុខសង្គមនៅក្នុងប្រទេសទាំងបី ១).ចាស់ជរា ពិការភាព និងឧត្តរជីវី ២).ជំងឺ និងមាតុភាព ៣).គ្រោះថ្នាក់ការងារ ៤).និកម្មភាព និង ៥).ប្រាក់ឧបត្ថម្ភគ្រួសារ។ ការសិក្សាលើកម្មវិធី/គម្រោង

នីមួយៗនឹងផ្តោតលើ ០៤ ចំណុច ដែលរួមមាន៖ ការគ្របដណ្តប់ ប្រភពនៃមូលនិធិ លក្ខខ័ណ្ឌតម្រូវ និង អត្ថប្រយោជន៍ផ្សេងៗ។ តារាងខាងក្រោមនេះពិភាក្សាពីការសិក្សាប្រៀបធៀបដូចតទៅ៖

**តារាង ៤.១ ការប្រៀបធៀបកម្មវិធីការគាំពារសង្គម**

| កម្មវិធី/គម្រោង | | ប្រទេសថៃ | ប្រទេសបារាំង | |
|---|---|---|---|---|
| ចាស់ជរា ពិការភាព និងឧត្តរជីវី | គ្របដណ្តប់ | *-សម្រាប់កម្មករនិយោជិតក្នុងប្រព័ន្ធ (ធានារ៉ាប់រងសង្គម)៖* ផ្តោតលើកម្មករនិយោជិត។<br><br>*- សម្រាប់កម្មករនយោជិកក្រៅប្រព័ន្ធ(ធានារ៉ាប់រងសង្គម និងមូលនិធិប្រាក់សន្សំរបស់ជាតិ)៖* កម្មវិធីនេះរួមបញ្ចូលអ្នកប្រកបរបរខ្លួនឯងនៅក្នុងវិស័យក្រៅប្រព័ន្ធ ឈរលើគោលការណ៍ស្ម័គ្រចិត្ត | *-ធានារ៉ាប់រងសង្គម៖* កម្មករនិយោជិកដែលធ្វើការនៅក្រុមហ៊ុន អ្នកប្រកបរបរផ្ទាល់ខ្លួនដែលមិនមែនជាវិស័យកសិកម្ម និងស្វាមី ឬភរិយាដែលរស់នៅពឹងផ្អែកលើមុខរបរប្តី ឬប្រពន្ធរបស់ខ្លួន។<br><br>*-ប្រាក់សោធននិវត្តន៍ការងារជាកាតព្វកិច្ច ៖* ដូចធានារ៉ាប់រងសង្គមខាងលើដែរ ប៉ុន្តែអ្នកប្រកបរបរផ្ទាល់ខ្លួនដែលមិនមែនជាវិស័យកសិកម្ម ត្រូវបានជំនួសដោយកម្មករដែលធ្វើការនៅក្នុងវិស័យកសិកម្ម និងទទួលបានប្រាក់បៀវត្សរ៍។<br><br>*-ជំនួយសង្គម៖* សម្រាប់តែនិវាសនជននៅប្រទេសបារាំងប៉ុណ្ណោះ។ | -កម្មវិ<br>(NP)<br>ប្រទេស<br>ឆ្នាំ ដល<br><br>-កម្មវិ<br>និយោ<br>និយោ<br>ដែលជ |
| | ប្រភពមូលនិធិ | *- កម្មករនិយោជិតក្នុងប្រព័ន្ធ៖* បង់វិភាគទាន ៣% នៃចំណូលសរុបប្រចាំខែ (អត្ថប្រយោជន៍សម្រាប់ពេលចាស់ជរា)។<br><br>*-អ្នកប្រកបមុខរបរផ្ទាល់ខ្លួន៖* ត្រូវបង់វិភាគទានក្នុងអត្រាថេរមួយគឺ ចំនួន ៥ ១៨៤បាតក្នុងមួយឆ្នាំចំពោះសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ប៉ុន្តែសម្រាប់អ្នកមានមុខរបរផ្ទាល់ខ្លួននៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធត្រូវបង់វិភាគទានចំនួន ៧០ ទៅ ១០០ ក្នុងមួយខែ។<br><br>*-និយោជក៖* បង់ ៣% នៃបញ្ជីបើកបៀវត្សរ៍ប្រចាំខែ (អត្ថប្រយោជន៍សម្រាប់ពេលចាស់ជរា) ។ | *សាមុីជន៖* អ្នកដែលស្ថិតនៅក្រោមធានារ៉ាប់រងសង្គមត្រូវបង់ប្រហែល ៧% នៃប្រាក់ចំណូលសរុបប្រចាំខែ (សម្រាប់អត្ថប្រយោជន៍ពេលចាស់ជរា និងសម្រាប់ឧត្តរជីវី) ហើយត្រូវបង់ ០,៤% នៃប្រាក់ចំណូលសរុបដើម្បីឧបត្ថម្ភដល់ឧត្តរជីវី។ ចំណែកឯអ្នកដែលស្ថិតនៅក្រោមគម្រោងប្រាក់សោធននិវត្តការងារជាកាតព្វកិច្ច ត្រូវបង់ ៣,១% ទៅ ៨,១% នៃប្រាក់ចំណូលសរុប។<br><br>*- សម្រាប់អ្នកប្រកបរបរផ្ទាល់ខ្លួន៖* អ្នកដែលស្ថិតនៅក្រោមរបបធានារ៉ាប់រងសង្គមត្រូវបង់វិភាគទានបន្ទាប់ពីឆ្នាំទី២ អ្នកប្រកបរបរផ្ទាល់ខ្លួនត្រូវបង់វិភាគទាន ១៧.៧៥% នៃចំណូលប្រចាំឆ្នាំរហូតដល់ពី ៣៩ ៧៣២អឺរ៉ូ និងត្រូវបង់បន្ថែម | -សាមុី<br>នក្នុងម<br><br>-សាមុី<br>ប្រាក់ខែ<br><br>-សម្រ<br>(NP)<br>ខែ។<br><br>-និយោ<br>បើកប្រ<br><br>-រាជរដ្ឋ<br>តម្លៃអ<br>ទាំងត្រ |

| | | | | |
|---|---|---|---|---|
| | | *-រាជរដ្ឋាភិបាល៖* ចូលរួមចំនួន ១% នៃចំណូលសរុបរបស់កម្មករនិយោជិកក្នុងប្រព័ន្ធ ដោយឡែករាជរដ្ឋាភិបាលចូលរួមចំនួ ៣០-៥០ បាត ក្នុងមួយខែសម្រាប់កម្មករនិយោជិកក្រៅប្រព័ន្ធម្នាក់។ | ០,៦% ទៀតប្រសិនបើប្រាក់ចំណូលប្រចាំឆ្នាំដែលបានប្រកាសលើសពីទឹកប្រាក់ដែលបានកំណត់ខាងលើ។ ចំណែកគម្រោងប្រាក់សោធននិវត្តការងារជាកាតព្វកិច្ច អ្នកប្រកបរបរផ្ទាល់ខ្លួន តម្រូវឱ្យបង់វិភាគទានចំនួន ៧% នៃប្រាក់ចំណូលប្រចាំឆ្នាំសរុបដែលបានប្រកាសរហូតដល់ ៣៩ ៧៣២អឺរ៉ូទៅ និងតម្រូវអោយបង់វិភាគទានបន្ថែម ៨% ប្រសិនបើប្រាក់ចំណូលនោះលើសពីទឹកប្រាក់ដែលបានកំណត់ខាងលើ។<br><br>-និយោជក៖ និយោជកដែលស្ថិតនៅក្រោមរបបធានារ៉ាប់រងសង្គមត្រូវបង់ ៨,៥% នៃប្រាក់បៀវត្សរ៍សរុប (ចាស់ជរា) និង១,៩% នៃបញ្ជីបើកប្រាក់បៀវត្សរ៍សរុប (ប្រាក់ឧបត្ថម្ភដល់ឧត្តរជីវី)។ បើស្ថិតក្រោមគម្រោងប្រាក់សោធននិវត្តការងារជាកាតព្វកិច្ច នយោជកអាចត្រូវបង់ ៤,៦៥% ដល់ ១២,៧៥% នៃបញ្ជីបើកប្រាក់បៀវត្សន៍ផ្អែកលើកម្មវិធី។<br><br>*-រដ្ឋាភិបាល៖* ចូលរួមផ្តល់វិភាគទានសម្រាប់កម្មវិធីរយៈពេលវែងសម្រាប់និកម្មជន (ក្រោមសេវាធានារ៉ាប់រងរបបសន្តិសុខសង្គម)។ នៅក្រោមកម្មវិធីជំនួយសង្គម រដ្ឋាភិបាលទទួលខុសត្រូវលើការចំណាយនៃគម្រោងសរុបដោយប្រើប្រាស់ពន្ធដែលបានមកពីប្រាក់ចំណូលរបស់បុគ្គល។ | *-រាជរដ្ឋ* ទាំងត្រ |
| | លក្ខខណ្ឌ តម្រូវ | *-សោធននិវត្តន៍សម្រាប់ចាស់ជរា៖ ចាប់ពីអាយុ ៥៥ឆ្នាំឡើងទៅ ប្រសិនបើគាត់បានបង់វិភាគទានចំនួន ១៨០ខែ។* | *-សោធននិវត្តន៍សម្រាប់ជនចាស់ជរា៖* អាយុចូលនិវត្តន៍តិចបំផុត ៦២ឆ្នាំ ប៉ុន្តែជាទូទៅអ្នកដែលចូលនិវត្តន៍នៅអាយុ | *-សម្រ* ឆ្នាំយ៉ា ហោច |

| | | | | |
|---|---|---|---|---|
| | | *-ជនពិការ៖* ពួកគាត់មិនមានការងារធ្វើ និងយ៉ាងហោចណាស់បានចូលរួមចំណែកបង់វិភាគទានយ៉ាងតិច ៣ ខែ មុនពេលគាត់ធ្លាក់ខ្លួនពិការ ក្នុងរយៈពេល ១៥ខែ ចុងក្រោយ។<br><br>*-អត្ថប្រយោជន៍សម្រាប់ឧត្តរជីវី៖* ទទួលបានអត្ថប្រយោជន៍ប្រសិនបើអ្នកដែលស្លាប់ទទួលមរណៈភាពមុនដល់អាយុចូលនិវត្តន៍។ | ៦៧ឆ្នាំនឹងទទួលបានប្រាក់សោធន៍និវត្តន៍ពេញលេញ។<br>*-សោធននិវត្តន៍សម្រាប់ជនពិការ៖* អាយុជនពិការដែលអាចទទួលបានប្រាក់សោធននិវត្តន៍មិនអាចទាបជាងអាយុចូលនិវត្តន៍ធម្មតាបានទេ ហើយយ៉ាងហោចណាស់គាត់បាត់បង់សមត្ថភាពបំពេញវិជ្ជាជីវៈ ៦៦,៧%។<br><br>*-សោធននិវត្តន៍សម្រាប់ប្តី ឬប្រពន្ធ៖* រួមបញ្ចូលទាំងស្ត្រីម៉េម៉ាយ ឬពោះម៉ាយដែលមានអាយុ ៥៥ឆ្នាំឡើងទៅអាចជាជនធម្មតា ឬជាជនពិការ។<br><br>*-ប្រាក់ឧត្តម្ភសម្រាប់មរណៈភាព៖* អ្នកស្លាប់ត្រូវតែជាកម្មករនិយោជិត ដែលទទួលបានអត្ថប្រយោជន៍និកម្មភាព ឬសោធននិវត្តន៍សម្រាប់ជនពិការមុនពេលស្លាប់។ | *-សម្រ*<br>៦០ (<br>កនោ<br>វិភាគទ<br><br>*-សោធ*<br>ត្រូវតែ<br>១ ឬក្រ<br><br>*-សោធ*<br>*(EPI)*<br>ថា ជា<br>*-សោធ*<br>អ្នកស្លា<br>សម្រា<br><br>*-សោធ*<br>អ្នកស្លា<br>ជរា និ<br>(EPI)<br>ឆ្នាំ។ |
| | អត្ថប្រយោជន៍ | *-សោធននិវត្តន៍សម្រាប់ចាស់ជរាក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ៖ និយោជិកក្រៅប្រព័ន្ធ៖* ទទួលបាន ២០% នៃប្រាក់ខែជាមធ្យមប្រចាំខែក្នុងអំលុងពេល ៦០ខែមុនពេលចូលនិវត្តន៍។<br><br>*-សោធននិវត្តន៍ពេលចាស់ជរាសម្រាប់កម្មករនិយោជិកក្រៅប្រព័ន្ធ៖* បង់ដោយផ្អែកលើសមតុល្យគណ- | *-សោធននិវត្តន៍សម្រាប់ជនចាស់ជរា៖* ជនដែលស្ថិតនៅក្រោមរបបធានារ៉ាប់រងសង្គមគឺ ទទួលបាន 50% នៃប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យម រួមទាំងទទួលបាននូវការធានារ៉ាប់រងកូននៅក្នុងបន្ទុកចំនួន ១០% បន្ថែមទៀត នៃប្រាក់សោធននិវត្តន៍សម្រាប់ជនចាស់ជរា។ ចំពោះអ្នកដែលស្ថិតនៅក្រោមគម្រោងប្រាក់សោធននិវត្តការងាជាកាតព្វកិច្ចត្រូវទទួលបានប្រាក់ធានារ៉ាប់រងដោយ | *-សោធ*<br>*(NP)*<br>មានចំ<br>ឆ្នាំ។<br><br>*-សោធ*<br>*(EPI)*<br>ខែជាម |

[2] ក្រុមទី១៖ ពិការភាពទាំងស្រុង និងតម្រូវឱ្យមានវត្តមានជាប្រចាំ
ក្រុមទី២៖  មានការកំណត់មិនឱ្យរស់នៅប្រកបដោយភាពឯករាជ្យតែឯងបាន
ក្រុមទី៣: មានការកំណត់មិនឱ្យមិនបំពេញការងារ។

| | | | | |
|---|---|---|---|---|
| | | នេយ្យជនដែលត្រូវធានារ៉ាប់រងនៅពេលចូលនិវត្តន៍<br><br>*-សោធននិវត្តន៍សម្រាប់ជនចាស់ជរា (ជំនួយសង្គម)៖* ទទួលបាន ៦០០-១ ០០០បាតក្នុងមួយខែ។<br><br>*-សម្រាប់ជនពិការអចិន្ត្រៃយ៍ក្នុងវិស័យក្រៅប្រព័ន្ធ៖* ទទួលបាន ៥០% នៃប្រាក់ឈ្នួលជាមធ្យមប្រចាំថ្ងៃខ្ពស់បំផុត ក្នុងអំលុងពេល ៣ខែមុនពេលពិការ។<br><br>*-សម្រាប់ជនពិការអចិន្ត្រៃយ៍ក្នុងវិស័យការងារក្រៅប្រព័ន្ធ៖* ទទួលបានចាប់ពី ៥០០បាត ទៅ ១ ០០០ បាត ផ្អែកលើចំនួនឆ្នាំដែលគាត់បានបង់វិភាគទាន។ សោធននិវត្តន៍នេះនឹងផ្តល់ជូនរហូតដល់រយៈពេល ១៥ ឆ្នាំ។<br><br>*-ឧត្តរជីវីរបស់កម្មករនិយោជិកក្នុងប្រព័ន្ធ៖* ទទួលបាន ១០ខែនៃប្រាក់សោធននិវត្តន៍ចាស់ជរាប្រចាំខែ។<br><br>*-ឧត្តរជីវីរបស់កម្មករនិយោជិកក្រៅប្រព័ន្ធ៖* ទទួលបានអត្ថប្រយោជន៍នូវថវិកាមួយកញ្ចប់ពីប្រាក់សោធននិវត្តន៍ចាស់ជរា និងសមតុល្យនៃការបង់វិភាគទានធានារ៉ាប់រងបន្ថែម (សម្រាប់ឧត្តរជីវីដែលមានសិទ្ធិប៉ុណ្ណោះ)។ | គិតតាមពិន្ទុនៃសោធននិវត្តន៍ ដែលកំណត់ទៅតាមរយៈពេលនៃការបង់វិភាគទាន គុណនឹងចំនួនប្រាក់សោធននិវត្តន៍នៅអាយុដែលគាត់ចូលនិវត្តន៍រួមជាមួយនឹងទឹកប្រាក់បន្ថែមសម្រាប់កូនៗចំនួន 10% នៃប្រាក់ខែបុគ្គលិក និង ៦% សម្រាប់អ្នកគ្រប់គ្រង។<br><br>*- សម្រាប់ជនពិការអចិន្ត្រៃយ៍៖* ប្រសិនបើធានារ៉ាប់រងវាយតម្លៃឃើញថាជននោះបានបាត់បង់សមត្ថភាពបំពេញវិជ្ជាជីវៈទាំងស្រុង គេនឹងទទួលបានធានារ៉ាប់រង 50% នៃប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំ ឬ30% ប្រសិនបើអ្នកដែលទទួលបានធានារ៉ាប់រងអាចមានលទ្ធភាពធ្វើសកម្មភាពមួយចំនួន។<br><br>*-អត្ថប្រយោជន៍សម្រាប់ឧត្តរជីវី៖* ទទួលបាន ៥៤% សម្រាប់ធានារ៉ាប់រងសង្គមផ្នែកសោធននិវត្តន៍ចាស់ជរា។ ទទួលបាន ៥០% នៃប្រាក់សោធននិវត្តការងារជាកាតព្វកិច្ច។ ឧត្តរជីវីអាចទទួលបានប្រាក់ឧត្តម្ភពីប្តី ឬប្រពន្ធរបស់ខ្លួនចំនួន ៦០៧,៥៤អឺរ៉ូ ក្នុងមួយខែ ក្នុងរយៈពេល ២ឆ្នាំ ព្រមទាំងប្រាក់ឧត្តម្ភមរណៈភាព (៩០ដងនៃប្រាក់ឈ្នួលប្រចាំថ្ងៃជាមធ្យមរបស់អ្នកស្លាប់ក្នុងកំឡុងពេលបីខែចុងក្រោយមុនពេលទទួលមរណៈភាព)។ | *-ពិការ*...<br>ទទួល...<br>ទី២ ទ...<br>ការផ្តល...<br>ពេល ...<br><br>*-ពិការ*...<br>១២៥...<br>កម្មករ ...<br><br>*-ឧត្តរជ*...<br>*៧៨០*...<br>*ពោះម៉*...<br>*ទាំងម្ត*...<br>*-ឧត្តរជ*...<br>បាន ...<br>ជរារប... |

| | | | | |
|---|---|---|---|---|
| ជំងឺ និង<br>មាតុភាព | គ្របដណ្តប់ | - វិស័យការងារក្នុងប្រព័ន្ធ៖ បុគ្គលដែលមានការងារធ្វើ<br><br>- វិស័យការងារក្រៅប្រព័ន្ធ៖ គ្របដណ្តប់លើអ្នកប្រកបរបរកស៊ីផ្ទាល់ខ្លួន តែទៅតាមការស្ម័គ្រចិត្តក្នុងវិស័យការងារក្រៅប្រព័ន្ធ<br><br>- *គម្រោងគ្របដណ្តប់ទូទាំងប្រទេស៖* ប្រជាពលរដ្ឋថៃស្ថិតនៅក្រោមគម្រោងធានារ៉ាប់រងសុខភាពរបស់រាជរដ្ឋាភិបាល | - អ្នកដែលមានការងារធ្វើ និងស្នាក់នៅក្នុងប្រទេសបារាំងយ៉ាងហោចណាស់៣ខែ<br><br>- អ្នកទទួលបានសោធននិវត្តន៍ទាំងអស់ដែលកំពុងរស់នៅក្នុងប្រទេសបារាំង ឬនៅក្រៅប្រទេស ត្រូវបានទទួលអត្ថប្រយោជន៍ខាងវេជ្ជសាស្ត្រ<br><br>- ប្រព័ន្ធពិសេសសម្រាប់មន្ត្រីរាជការ ឧស្សាហកម្មកសិកម្ម ធនធានរ៉ែ ផ្លូវដែក បព្វជិត កម្មករនាវា និងអ្នកធ្វើការផ្នែកកសិកម្មដោយខ្លួនឯង | - *ធានា*<br>ប្រទេស<br><br>- *ធានា*<br>*និយោ*<br>រ៉ាប់រង<br>ដែលម<br>នាក់<br><br>- *ការ*<br>*មនុស្*<br>ឆ្នាំ ឬ<br>ដែលម |
| | ប្រភពមូលនិធិ | - *សាម៉ីជនក្នុងវិស័យការងារក្នុងប្រព័ន្ធ៖* ១.០៦% នៃប្រាក់ចំណូលសរុបប្រចាំខែ (ជំងឺ និងមាតុភាព) ០.៤% (ជនពិការ និងឧត្តរជីវី)<br><br>- *អ្នកប្រកបមុខរបរផ្ទាល់ខ្លួន៖* ដូចគ្នានឹងផ្នែកខាងលើមនុស្សចាស់ ពិការភាព ឧត្តជីវី<br><br>- និយោជក៖ ១.០៦% នៃបញ្ជីប្រាក់បៀវត្សប្រចាំខែ (ជំងឺ និងមាតុភាព) ០.៤% (ពិការភាព និងឧត្តជីវី) សម្រាប់វិស័យការងារក្នុងប្រព័ន្ធ។ សម្រាប់វិស័យការងារក្រៅប្រព័ន្ធ គឺស្ថិតនៅក្រោមគម្រោងគ្របដណ្តប់នៃការធានារ៉ាប់រងសុខភាពជាសកល | -*សាម៉ីជន៖* គ្មាន<br><br>-*អ្នកប្រកបមុខរបរផ្ទាល់ខ្លួន៖* ពី ០%ទៅ ៦.៥% នៃប្រាក់ចំណូលដែលបានប្រកាសលើប្រាក់ចំណូលរបស់អ្នកទទួលបានធានារ៉ាប់រង និងវិជ្ជាជីវៈ<br><br>- *និយោជក៖*១៣.៣% នៃបញ្ជីប្រាក់បៀវត្សរ៍<br>-*រដ្ឋាភិបាល៖* រួមចំណែកសម្រាប់បញ្ហានិកម្មភាពរយៈវែង | - សាម៉ី<br>១៤២<br>នីមួយ<br><br>- សាម៉ី<br>ប្រចាំ<br>ទាំង៥<br><br>- *អ្នក*<br>យ៉េន។<br>៦៦ ៧<br>សម្រា<br><br>- និយោ<br>ចំណូ<br>ប្រាក់<br><br>- រដ្ឋាភិ<br>ថ្នាក់ជ<br>ចំណា |

| | | | | |
|---|---|---|---|---|
| | លក្ខខ័ណ្ឌតម្រូវ | - *ប្រាក់សម្រាប់ជំងឺនិងអត្ថប្រយោជន៍ខាងវេជ្ជសាស្ត្រក្នុងវិស័យការងារក្នុងប្រព័ន្ធ*៖ ត្រូវមានវិភាគទានយ៉ាងហោចណាស់បីខែ ក្នុងរយៈពេល១៥ខែចុងក្រោយមុនពេលការព្យាបាលចាប់ផ្ដើម<br><br>- *ប្រាក់សម្រាប់ជំងឺក្នុងវិស័យការងារក្រៅប្រព័ន្ធ*៖ ត្រូវមានវិភាគទានយ៉ាងហោចណាស់៣ខែ ក្នុងរយៈពេល៤ខែចុងក្រោយ មុនពេលមានជំងឺ ឬរងរបួស<br><br>- *ប្រាក់មាតុភាព ប្រាក់ឧបត្ថម្ភសម្រាលកូន និងអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រក្នុងវិស័យការងារក្នុងប្រព័ន្ធ*៖ ត្រូវមានវិភាគទានយ៉ាងហោចណាស់៥ខែក្នុងរយៈពេល១៥ខែចុងក្រោយ មុនពេលសម្រាលកូន | - *ប្រាក់សម្រាប់ជំងឺ*៖ ត្រូវបំពេញលក្ខខ័ណ្ឌយ៉ាងហោចណាស់បំពេញការងារ១៥០ម៉ោងក្នុងរយៈពេលបីខែចុងក្រោយ មុនពេលឈប់សម្រាកឈឺ<br><br>- *ប្រាក់មាតុភាព*៖ ត្រូវមានវិភាគទានយ៉ាងហោចណាស់ រយៈពេល១០ខែ និងបំពេញការងារ១៥០ម៉ោង ក្នុងរយៈពេលបីខែចុងក្រោយ មុនលិខិតបញ្ជាក់មានផ្ទៃពោះ<br><br>-*បិតុភាព*៖ ត្រូវបង់ឱ្យឪពុករបស់កូនដែលបានបង់វិភាគទានយ៉ាងហោចណាស់រយៈពេល ១០ខែ<br>-*អត្ថប្រយោជន៍ខាងវេជ្ជសាស្ត្រ*៖ ត្រូវតែមានការងារធ្វើយ៉ាងហោចណាស់ក្នុងរយៈពេល៦០ម៉ោងក្នុងរយៈពេលមួយខែចុងក្រោយ | - *ការជ*<br>*ថែទាំ*<br>តែរស់<br><br>- *ការជ*<br>៖ ត្រូវ |
| | អត្ថប្រយោជន៍ | - *អត្ថប្រយោជន៍ពេលមានជំងឺក្នុងវិស័យការងារក្នុងប្រព័ន្ធ*៖ ទទួលបាន ៥០% នៃប្រាក់ប្រចាំថ្ងៃជាមធ្យមដែលខ្ពស់បំផុតក្នុងរយៈពេលបីខែ នៃ៩ខែចុងក្រោយ មុនពេលមានជំងឺ<br><br>-អត្ថប្រយោជន៍ពេលមានជំងឺក្នុងវិស័យការងារក្រៅប្រព័ន្ធ៖ ទទួលបាន ២០០បាត ក្នុងមួយថ្ងៃ ហើយត្រូវផ្ដល់ឲ្យរហូតដល់៣០ថ្ងៃក្នុងមួយឆ្នាំ<br><br>- *ប្រាក់ឧបត្ថម្ភមាតុភាពនិងសម្រាលកូនក្នុងវិស័យការងារក្នុងប្រព័ន្ធ*៖ ៥០% នៃប្រាក់ប្រចាំថ្ងៃជាមធ្យម | -*អត្ថប្រយោជន៍ពេលមានជំងឺ*៖ ទទួលបាន៥០% នៃប្រាក់ចំណូលប្រចាំថ្ងៃក្នុងរយៈពេលបីខែចុងក្រោយ មុនពេលឈឺ ហើយនឹងកើនដល់ ៦៦.៧% បើគាត់មានកូនក្នុងបន្ទុកបីនាក់ រហូតដល់ ៦ ឬ១២ខែ ដោយផ្អែកអតីតភាពការងារ<br><br>- *អត្ថប្រយោជន៍មាតុភាព*៖ ទទួលបាន ១០០% នៃប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យមក្នុងរយៈពេលបីខែចុងក្រោយ មុនពេលសម្រាលកូន<br><br>-*អត្ថប្រយោជន៍វេជ្ជសាស្ត្ររបស់កម្មករនិយោជិត*៖ អត្ថប្រយោជន៍រួមទាំងការ | -*ជំងឺ(*<br>និងកា<br>សពទេ<br><br>- *ជំងឺ*<br>ប្រាក់ព<br><br>-*កម្មក*<br>ទទួល<br>ថែទាំ<br>វេជ្ជសា<br>ព្យាបា<br>ថែទាំម<br>រំលែក |

| | | | | |
|---|---|---|---|---|
| | | ដែលខ្ពស់បំផុតក្នុងរយៈពេល ៣ខែនៃ៩ខែចុងក្រោយ និងការផ្តល់ទឹកប្រាក់ចំនួន១៣ ០០០បាត ក្នុងកូនម្នាក់<br><br>-*ការថែទាំផ្នែកវេជ្ជសាស្ត្ររបស់កម្មករនិយោជិតក្នុងវិស័យការងារក្នុងប្រព័ន្ធ៖* រួមទាំងការពិនិត្យនិងព្យាបាល ការថែទាំសុខភាព និងការសម្រាកព្យាបាល<br><br>-*ការថែទាំផ្នែកវេជ្ជសាស្ត្ររបស់អ្នកក្នុងបន្ទុកក្នុងវិស័យការងារក្រៅប្រព័ន្ធ* ៖ ការថែទាំសុខភាពដែលចាំបាច់ទាក់ទងនឹងការសម្រាលកូនសម្រាប់ប្រពន្ធ ឬស្ត្រីដែលរួមរស់ជាមួយបុរស | ថែទាំព្យាបាលទូទៅនិងពិសេស ការសម្រាកព្យាបាល ឱសថ ការថែទាំភ្នែក និងធ្មេញ ការថែទាំសម្ភព គ្រឿងប្រើប្រាស់ និងការដឹកជញ្ជូន<br><br>- *អត្ថប្រយោជន៍របស់កូនក្នុងបន្ទុក៖* ទទួលបានសាម៉ីជនដែរ | |
| គ្រោះថ្នាក់ការងារ | គ្របដណ្តប់ | -កម្មករនិយោជិត នៃក្រុមហ៊ុនឧស្សាហកម្ម និងពាណិជ្ជកម្ម។ មានប្រព័ន្ធពិសេស ដោយឡែកសម្រាប់មន្ត្រីរាជការ និងបុគ្គលិកសាលាឯកជន | អ្នកធ្វើការងារ និស្សិត និងអ្នកស្វែងរកការងារធ្វើ និងគ្របដណ្តប់ទៅលើពលរដ្ឋបារាំងដែលធ្វើការនៅបរទេសដែរ តែឈរលើគោលការណ៍ស្ម័គ្រចិត្ត។ គម្រោងនេះ មិនគ្របដណ្តប់លើអ្នកប្រកបរបរផ្ទាល់ខ្លួនទេ។ | - អ្នកធ្វើ<br><br>- អ្នកប្រ<br>ចំនួន<br><br>- ប្រព័ |
| | ប្រភពមូលនិធិ | - *និយោជក៖* ពី ០.២% ទៅ ១% យោងទៅតាមកម្រិតហានិភ័យ | -*និយោជក៖* បង់ថ្លៃសរុប | -*អ្នកប្រ*<br>ទៅ ៥.<br>ប្រចាំខែ<br>- *និយោ*<br>ប្រាក់បៀ<br>ជំនួញ<br>- រដ្ឋាភិ<br>ចាំបាច់ |
| | លក្ខខ័ណ្ឌតម្រូវ | -មិនមានពេលវេលាកំណត់ | -ឧបទ្ទវហេតុដែលកើតឡើង នៅពេលធ្វើដំណើរទៅធ្វើការ និងធ្វើការ | -មិនមា |

| | | | | |
|---|---|---|---|---|
| | អត្ថប្រយោជន៍ | - *ពិការភាពបណ្ដោះអាសន្ន៖* ទទួលបាន៦០% នៃប្រាក់ឈ្នួលប្រចាំខែមុនពេលពិការ<br><br>- *ពិការភាពអចិន្ត្រៃយ៍:* ចំពោះពិការភាព១០០% នឹងទទួលបាន៦០% នៃប្រាក់ឈ្នួលជាមធ្យម មុនពេលពិការរហូតដល់១៥ឆ្នាំ<br><br>-*ការថែទាំវេជ្ជសាស្ត្ររបស់កម្មករនិយោជិត៖*ទទួលបានរហូតដល់ ៤៥ ០០០បាតសម្រាប់ឧប្បត្តិហេតុការងារនីមួយៗ និងរហូតដល់ ៣០០ ០០០បាតក្នុងករណីពិសេសជាក់លាក់ និង២០ ០០០បាតសម្រាប់សេវាកម្មស្ដារនីតិសម្បទា<br>- ឧត្តរជីវិ៖ ទទួលបាន ៦០% នៃប្រាក់ឈ្នួលប្រចាំខែចុងក្រោយរបស់អ្នកស្លាប់រហូតដល់៨ឆ្នាំ | - *ពិការភាពបណ្ដោះអាសន្ន៖* ទទួលបាន៦០% នៃប្រាក់ឈ្នួលប្រចាំថ្ងៃក្នុងរយៈពេល២៨ថ្ងៃដំបូង និងកើនទៅដល់ ៨០% បន្ទាប់ពីថ្ងៃទី២៩ រហូតដល់ជាសះស្បើយ ឬ លិខិតបញ្ជាក់ពីការពិការភាពអចិន្ត្រៃយ៍<br><br>- *ពិការអចិន្ត្រៃយ៍៖*ទទួលបាន១០០% នៃប្រាក់ចំណូលប្រចាំឆ្នាំ ប្រសិនពិការទាំងស្រុង<br><br>- *ខាងការថែទាំវេជ្ជសាស្ត្ររបស់កម្មករនិយោជិត៖* រួមមានការព្យាបាលនិងការវះកាត់ ការសម្រាកព្យាបាល គ្រឿងប្រើប្រាស់ ការស្ដារនីតិសម្បទា និងការដឹកជញ្ជូន មូលនិធិនៃជំងឺគ្របដណ្ដប់សេវាទាំងអស់ដោយផ្ទាល់<br><br>- អត្ថប្រយោជន៍របស់ឧត្តរជីវិ៖ទទួលបាន៤០% នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់អ្នកស្លាប់ | - *ពិកា*<br>៦០%<br>២០%<br>រយៈពេ<br>ស្បើយ<br><br>- *ពិកា*<br>និវត្តន៍<br>ពិការភ<br><br>- *ការថែ*<br>*និយោ*<br>សម្រា<br>និងថែ<br>ការទទួ<br>កំណត់<br>- ឧត្តរ<br>និវត្តន៍<br>ជាគោ<br>២៤៥ |
| និកម្មភាព | គ្របដណ្ដប់ | អ្នកមានការងារ | -អ្នកដែលមានការងារធ្វើទាំងអស់ដែលរស់នៅក្នុងប្រទេសបារាំង ឬនៅម៉ូណាកូ រួមទាំង អ្នកផ្ដល់ការថែទាំកុមារ អ្នកធ្វើការតាមផ្ទះ និងកូនជាង( apprentices )<br><br>-លើកលែង៖ មន្ត្រីរាជការស៊ីវិល និងអ្នកប្រកបមុខរបរផ្ទាល់ខ្លួន | -អ្នកម<br>ឆ្នាំ<br><br>-ប្រព័ន្ធ<br>និងកម្ម |
| | ប្រភពមូលនិធិ | -*សាម៉ីជន៖* ០.៥% នៃប្រាក់ចំណូលប្រចាំខែ<br><br>-*និយោជក៖* ០.៥% នៃបញ្ជីប្រាក់ខែ | - *សាម៉ីជន(ការធានារ៉ាប់រងសង្គម)៖* ០.៩៥% នៃប្រាក់ចំណូលសរុប<br><br>- *និយោជក (ការធានារ៉ាប់រងសង្គម)៖* ៤.០៥% នៃបញ្ជីប្រាក់បៀវត្ស និង ០.១៥% នៃប្រាក់បៀវត្ស ដើម្បីគាំទ្រ | -*សាម៉ី*<br>ប្រចាំខែ<br>កសិក<br>ឧស្សា |

| | | | | |
|---|---|---|---|---|
| | | - *រដ្ឋាភិបាល៖* ០.២% នៃប្រាក់ចំណូលប្រចាំខែ | មូនិធិធានារ៉ាប់រងប្រាក់បៀវត្ស ប្រសិនបើនិយោជកបានជួបក្ស័យធន | - *និយេ* បៀវត្ស កសិក បៀវ និ - *រដ្ឋាភិ* ប្រយោ អត្ថប្រ សម្រា សម្រា សម្រា |
| | លក្ខខ័ណ្ឌតម្រូវ | - ត្រូវមានវិភាគទានយ៉ាងតិច៦ខែ ក្នុង១៥ខែ មុនអត់ការងារធ្វើ | មិនត្រូវលើសពីអាយុចូលនិវត្តន៍ និងយ៉ាងតិចចំនួន ៨៨ថ្ងៃ នៃការបង់វិភាគទានក្នុងរយៈពេល១៨ខែចុងក្រោយ មុនពេលអត់ការងារធ្វើ | - *និកម្ម* ហោច ខែចុង -*កម្មក* ករដែល - *ការ* ទទួល ១៨ខែ |
| | អត្ថប្រយោជន៍ | ទទួលបាន៥០% នៃប្រាក់ឈ្នួលជាមធ្យមប្រចាំថ្ងៃ លើប្រាក់ខែខ្ពស់បំផុតរយៈពេល ៣ ខែ ក្នុងរយៈពេល៩ ខែមុនពេលអត់ការងារធ្វើហូតដល់ ១៨០ ថ្ងៃ សម្រាប់អ្នកអត់ការងារធ្វើដោយមិនស្ម័គ្រចិត្ត។ ចំពោះអ្នកដែលអត់ការងារធ្វើដោយសារស្ម័គ្រចិត្ត នឹងទទួលបាន៣០% នៃប្រាក់ឈ្នួលប្រចាំឆ្នាំជាមធ្យម រហូតដល់ ៩០ថ្ងៃ។ | ទទួលបាន៥៧%ទៅ ៧៥% នៃប្រាក់ចំណូលប្រចាំថ្ងៃ ក្នុងរយៈពេល១២ ខែចុងក្រោយ។ រយៈពេលទទួលអត្ថប្រយោជន៍ទៅតាមចំនួនខែដែលបុគ្គលនេះបានបង់វិភាគទានរហូតដល់ ២៤ខែ ហើយកើនដល់ ៣៦ខែ ប្រសិនបើមានអាយុលើសពី៥០ឆ្នាំ | - *និកម្ម* ៨០% ក្នុងរយ ប្រសិន ទទួល - *កម្មក* ប្រាក់ អាស្រ័ ឈ្នួល - *ការ* បាន៦ មធ្យម ដោយ |

| | | | | |
|---|---|---|---|---|
| | | | | ខែដំបូ<br>៥០%<br><br>- *អត្ថប្រ*<br>ទទួល<br>មុនពេ<br>គ្រួសារ |
| ប្រាក់ឧបត្ថម្ភគ្រួសារ | គ្របដណ្តប់ | បុគ្គលិក | ប្រជាពលរដ្ឋរបស់ប្រទេសបារាំង | អ្នកដែ<br>ពីរ ដែ<br>វិទ្យាល័ |
| | ប្រភពមូលនិធិ | មើលប្រភពនៃមូលនិធិ ផ្តល់អោយមនុស្សចាស់ ពិការភាព និងឧត្តរជីវីខាងលើ | -*សាមុីជន៖* "គ្មាន"<br>-*អ្នកប្រកបមុខរបរផ្ទាល់ខ្លួន៖* ២,១៥% ទៅ ៥,២៥% នៃចំណូលដែលបានប្រកាស អាស្រ័យទៅតាមកម្រិតនៃប្រាក់ចំណូលនោះ<br>-*និយោជក៖* ៣,៤៥% នៃបញ្ជីប្រាក់បៀវត្សរ៍ រហូតដល់ ៣,៥ ដង នៃប្រាក់ខែអប្បបរមា ហើយកើនដល់៥,២៥% សម្រាប់ប្រាក់ចំណូលដែលលើស ៣,៥ ដង នៃប្រាក់ខែអប្បបរមា។<br>-*រដ្ឋាភិបាល៖* ផ្តល់ការឧបត្ថមធនជាវិភាគទានសម្រាប់អ្នកអត់មានការងារធ្វើរយៈពេលវែង។ | -*និយោ*<br>នៃប្រា<br>អាយុព<br><br>-*រដ្ឋាភិ*<br>ក្រោម<br>វិភាគទ<br>រដ្ឋបាល<br>សម្រាប<br>ដល់១<br>ខ្លួន និ<br>រាល់កា<br>ជាតិ ៦<br>១៧% |
| | លក្ខខ័ណ្ឌតម្រូវ | *ការឧបត្ថម្ភកូន៖* ការបង់វិភាគទានយ៉ាងហោចណាស់មានរយៈពេល ១២ខែ នៅក្នុងរយៈពេល ៣៦ខែ មុនពេលទទួលបានប្រាក់ឧបត្ថម្ភ | *ឧបត្ថម្ភគ្រួសារ៖* ត្រូវមានកូនក្នុងបន្ទុកពីរឬច្រើននាក់ ដែលមានអាយុក្រោម ២០ឆ្នាំ<br>*កុមារភាព*៖ បង់សម្រាប់ទារកទើបនឹងកើត និងកូនចិញ្ចឹម។ | ត្រូវមាន<br>លានរ<br>ក្នុងមួយ<br>កូន ០ |
| | អត្ថប្រយោជន៍ | *ប្រាក់ឧបត្ថមកូន៖* កូនម្នាក់ៗទទួលបានចំនួន ៤០០បាត(bath) រៀងរាល់ខែ | -*ប្រាក់ឧបត្ថម្ភគ្រួសារ៖* ចំនួនដែលទទួលបានប្រែប្រួលទៅតាមចំនួនកូន និងប្រាក់ចំណូលរបស់គ្រួសារ | -កុមារ<br>បានចំ<br>-សម្រា<br>ចាប់ពី |

| | | | | |
|---|---|---|---|---|
| | | | -កុមារភាព៖ មានអត្ថប្រយោជន៍៤ផ្សេងគ្នាទៀត<br><br>*-ប្រាក់ឧបត្ថម្ភពីឪពុកម្តាយសម្រាប់កុមារឈឺ៖* ទទួលបានការចំណាយប្រចាំថ្ងៃចំនួន € ៤៣,១៤ រហូតដល់ ២២ ថ្ងៃក្នុងមួយខែ។<br><br>*ប្រាក់ឧបត្ថម្ភគ្រួសារ៖* មានចំនួន €១០៩ក្នុងមួយខែ សម្រាប់ឪពុក ឬម្តាយដែលចិញ្ចឹមកូនម្នាក់ឯង | សិក្សា<br>ក្នុងមួយ |

*ប្រភព៖ សមាគមរបបសន្តិសុខសង្គមអន្តរជាតិ ២០១៨*

## ៤-២ ការចំណាយសម្រាប់វិស័យសុខាភិបាល និងកម្មវិធីគាំពារសង្គម កម្ពុជា ថៃ បារាំង និងជប៉ុន

តារាងទី ៤.២ ខាងក្រោមបង្ហាញពីការចំណាយទៅលើវិស័យសុខាភិបាល នឹងការគាំពារសង្គម ជាចំណែកផ.ស.ស ក្នុងប្រទេសចំនួន៤ រួមមាន ប្រទេសថៃ ប្រទេសជប៉ុន ប្រទេសបារាំង និងប្រទេសកម្ពុជា។ គួរកត់សម្គាល់ផងដែរថា ការចំណាយរបស់កម្ពុជាទៅលើផ្នែកគាំពារសង្គមមិនមានទិន្នន័យបង្ហាញទេ។ គេសង្កេតឃើញថាការចំណាយផ្នែកសុខាភិបាលនៅប្រទេសបារាំង នឹងប្រទេសជប៉ុនប្រហាក់ប្រហែលគ្នា គឺប្រមាណ ៧,៣% នៃផ.ស.ស គិតជាមធ្យមក្នុងចន្លោះឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ និងចំនួននេះខ្ពស់ជាងគេក្នុងចំណោម៤ប្រទេស ស្របពេលដែលការចំណាយរបស់រាជរដ្ឋាភិបាលថៃ និងកម្ពុជា មានត្រឹម ២,៧% និង១,៣% នៃផ.ស.ស ដែលគិតជាមធ្យមក្នុងរយៈពេលដូចគ្នា។

ប្រសិនបើយើងពិនិត្យមើលលើការចំណាយសម្រាប់កម្មវិធីគាំពារសង្គម ឃើញថាប្រទេសបារាំងនាំមុខក្នុងចំណោម ៤ប្រទេស ដែលការចំណាយនេះមានរហូតដល់ទៅ ៣,៤% នៃ ផ.ស.ស គិតជាមធ្យមក្នុងឆ្នាំ ២០១៣ ដល់ឆ្នាំ២០១៦ ជប៉ុនលំដាប់ទី២ មានចំនួន ២,៥% នឹងថៃ ០,២% នៅក្នុងរយៈពេលដូចគ្នា។

**តារាងទី៤.២៖ ចំណែកនៃចំណាយវិស័យសុខាភិបាល នឹងគាំពារសង្គមធៀបនឹងផ.ស.ស(%)**

| ប្រទេស | ការចំណាយ | 2013 | 2014 | 2015 | 2016 | មធ្យម |
|---|---|---|---|---|---|---|
| បារាំង | សុខាភិបាល | 7.2 | 7.3 | 7.3 | 7.3 | 7.3 |
| | គាំពារសង្គម | 3.4 | 3.4 | 3.4 | 3.4 | 3.4 |
| ជប៉ុន | សុខាភិបាល | 7.4 | 7.4 | 7.4 | 7.3 | 7.3 |
| | គាំពារសង្គម | 2.5 | 2.6 | 2.5 | 2.6 | 2.5 |
| ថៃ | សុខាភិបាល | 2.6 | 2.8 | 2.6 | 2.8 | 2.7 |
| | គាំពារសង្គម | 0.2 | 0.2 | 0.2 | 0.2 | 0.2 |
| កម្ពុជា | សុខាភិបាល | 1.4 | 1.2 | 1.3 | 1.3 | 1.3 |
| | គាំពារសង្គម | N/A | N/A | N/A | N/A | N/A |

*ប្រភព៖ ស្ថិតិរបស់អង្គការសហប្រជាជាតិ,២០១៨[14]*

## ៥- ចំណុចពិភាក្សា

ការពិភាក្សានៅក្នុងផ្នែកនេះគឺយោងទៅតាមតារាងទី២.២ តារាង៤.១ និងតារាង៤.២ ខាងលើ។ ចំណុចពិភាក្សាមានដូចខាងក្រោមនេះ៖

១- គ្រប់ប្រទេសទាំងអស់ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ បានអនុវត្តកម្មវិធីគាំពារសង្គមដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋទោះជាប្រទេសអភិវឌ្ឍន៍ ឬប្រទេសកំពុងអភិវឌ្ឍន៍។

កម្មវិធីនេះរួមមាន៖ ប្រាក់សោធននិវត្តន៍សម្រាប់ជនចាស់ជរា (រដ្ឋ និងឯកជន) អត្ថប្រយោជន៍សម្រាប់ឧត្តរជីវី ពិការភាព គ្រោះថ្នាក់ការងារ ភាពអត់មានការងារធ្វើ និងប្រាក់ឧបត្ថម្ភគ្រួសារ។

២- គួរកត់សម្គាល់ផងដែរថាខណៈដែលប្រទេសអភិវឌ្ឍន៍ មិនបានលើកឡើងឡើយពាក់ព័ន្ធនឹងអត្ថប្រយោជន៍សម្រាប់វិស័យការងារក្រៅប្រព័ន្ធ ពីកម្មវិធីរបបសន្តិសុខសង្គម តែប្រទេសកំពុងអភិវឌ្ឍន៍បាននឹងកំពុងយកចិត្តទុកដាក់លើវិស័យនេះដូចជាប្រទេសថៃ និងប្រទេសកម្ពុជាជាដើម។ ទាំងនេះអាចជាមេរៀនសម្រាប់ប្រទេសដ៏ទៃផ្សេងទៀតពិសេសប្រទេសកំពុងអភិវឌ្ឍន៍ នៅពេលដែលអនុវត្តកម្មវិធីគាំពារសង្គម ក្នុងនោះអ្នកដែលធ្វើការនៅក្នុងវិស័យក្រៅប្រព័ន្ធ គឺជាក្រុមគោលដៅមួយសំខាន់ក្នុងការដាក់បញ្ចូលទៅក្នុងកម្មវិធីគាំពារសង្គម។

៣- ខណៈពេលដែលប្រទេសបីទៀតអនុវត្តគម្រោងធានារ៉ាប់រងលើភាពអត់ការងារធ្វើនៅក្រោមកម្មវិធីធានារ៉ាប់រងសង្គម ក៏ប៉ុន្តែកម្ពុជាមិនបានអនុវត្តកម្មវិធីនេះនៅឡើយទេ តែកម្ពុជាបានអនុវត្តការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(TVET) ដើម្បីបង្កើនជំនាញបច្ចេកទេសសម្រាប់យុវជនដែលបានបោះបង់ការសិក្សា។ កម្ពុជាអាចពិចារណាទៅលើការអនុវត្តគោលនយោបាយធានារ៉ាប់រងលើភាពអត់ការងារធ្វើនាពេល អនាគត។

៤- ទាក់ទងទៅនឹងប្រភពនៃមូលនិធិក្នុងការអនុវត្តធានារ៉ាប់រងសង្គម គ្រប់ភាគី ក្នុងនោះរួមមាននិយោជិត និយោជក អ្នកប្រកបមុខរបរផ្ទាល់ខ្លួន និងរដ្ឋាភិបាល ត្រូវរួមវិភាគទានក្នុងកម្មវិធីធានារ៉ាប់រងសង្គម ដើម្បីធានានូវនិរន្តភាពនៃកម្មវិធីនេះ។ ចំណុចនេះ កម្ពុជាអាចពិចារណាលើវិភាគទានអ្នកប្រកបមុខរបរផ្ទាល់ខ្លួនសម្រាប់កម្មវិធីធានារ៉ាប់រងសង្គម ដោយសារគោលនយោបាយរបស់កម្ពុជាមិនបានផ្តោតឡើយទៅលើក្រុមគោលដៅប្រភេទនេះ នៅក្នុងកម្មវិធី។

៥- រដ្ឋាភិបាលជប៉ុនមានកាតព្វកិច្ចចូលរួមវិភាគទានការចំណាយទៅលើអត្ថប្រយោជន៍សម្រាប់ប្រាក់សោធននិវត្តន៍សម្រាប់ជនចាស់ជរា ពិការភាព និងឧត្តរជីវីប្រមាណ៥០% និងចំណាយរដ្ឋបាល និង ៥០% សម្រាប់អត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ។

៦- វាក៏ត្រូវបានកត់សម្គាល់ផងដែរនូវការចូលរួមវិភាគទានពីសាម៉ីជននៃប្រទេសអភិវឌ្ឍន៍មានដូចជាបារាំងនិងជប៉ុនគឺខ្ពស់ជាងវិភាគទានពីសាម៉ីជនបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជានិងថៃ។ វិភាគទានពីសាម៉ីជនសម្រាប់សោធននិវត្តន៍ ពិការភាព និងឧត្តរជីវី នៃប្រទេសបារាំងមានចំនួន ៧% នៃប្រាក់ចំណូលសរុបប្រចាំខែ ជប៉ុន៩% និងថៃមាន៣%។ កម្ពុជាមិនទាន់បានអនុវត្តនៅឡើយសម្រាប់សោធននិវត្តន៍របស់និយោជិតផ្នែកឯកជនតែនឹងអនុវត្តក្នុងឆ្នាំ២០១៩ តែកម្មវិធីនេះបានអនុវត្តសម្រាប់មន្ត្រីសាធារណៈ។ ប៉ុន្តែសម្រាប់កម្ពុជា ការផ្តល់ប្រាក់សោធននិវត្តន៍សម្រាប់មន្ត្រីរាជការត្រូវបានឧបត្ថម្ភធនទាំងស្រុងពីរដ្ឋាភិបាល មិនមានវិភាគទានពីសាម៉ីជននៅឡើយទេ។

៧- ទាក់ទងទៅនឹងធានារ៉ាប់រងផ្នែកជំងឺ និងមាតុភាព រដ្ឋាភិបាលជប៉ុនរួមវិភាគទានចំណាយសម្រាប់ការថែទាំផ្នែកវេជ្ជសាស្ត្រហូតដល់ ៥០% ក៏ប៉ុន្តែការចំណាយនេះត្រូវបានបែងចែកគ្នារវាងថ្នាក់

ជាតិ និងថ្នាក់ខេត្ត(៩១%ថ្នាក់ជាតិ ៩%ថ្នាក់ខេត្ត)។ នេះអាចជាការអនុវត្តល្អដើម្បីជាការចែករំលែកក្នុងការទទួលខុសត្រូវរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

៨- ករណីប្រទេសបារាំងបានឆ្លុះបញ្ចាំងឲ្យឃើញថា ប្រទេសនេះបានយកពន្ធលើប្រាក់ចំណូលបុគ្គលិកដើម្បីទៅបង់វិភាគទានក្នុងកម្មវិធីជំនួយសង្គម។ ដោយសារកម្មវិធីជំនួយសង្គមនៅប្រទេសកម្ពុជាភាគច្រើននៃប្រភពមូលនិធិត្រូវបានពឹងផ្អែកយ៉ាងខ្លាំងលើដៃគូអភិវឌ្ឍន៍ ហេតុដូចនេះកាអនុវត្តប្រទេសបារាំងអាចនឹងត្រូវបានពិចារណាសម្រាប់ការអនុវត្តនាពេលអនាគតក្នុងប្រទេសកម្ពុជា។

៩- និយោជកនៅប្រទេសថៃនិងប្រទេសជប៉ុន បានធ្វើការបង់ធានារ៉ាប់រងគ្រោះថ្នាក់ការងារជាមួយភាគរយក្នុងកម្រិតណាមួយនៃប្រាក់បៀវត្សរ៍អាស្រ័យទៅតាមប្រភេទនៃអាជីវកម្មនីមួយៗ ខណៈដែលប្រទេសកម្ពុជា និយោជកបានបង់ធានារ៉ាប់រងគ្រោះថ្នាក់ការងារក្នុងអត្រាថេរគឺ ០,៨% នៃប្រាក់បៀវត្សរ៍។

១០- ប្រទេសបារាំងនៅតែជាប្រទេសនាំមុខគេក្នុងការចំណាយក្នុងកម្មវិធីគាំពារសង្គមដែលមានចំនួន ៣,៤%នៃផ.ស.ស បន្ទាប់មកប្រទេសជប៉ុន មានចំនួន ២,៥% នៃផ.ស.ស និង០,២%ប្រទេសថៃ។

## ៦- សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការយកចិត្តទុកដាក់ជាបន្តបន្ទាប់ ទៅលើកម្មវិធីគាំពារសង្គមដើម្បីលើកកម្ពស់គុណភាពជីវិត ដោយបានដាក់ចេញនូវក្របខ័ណ្ឌគោលនយោបាយគាំពារសង្គមឆ្នាំ ២០១៦-២០២៥ ដែលផ្តោតលើសសរស្តម្ភចំនួនពីរគឺជំនួយសង្គម និងការធានារ៉ាប់រងសង្គម។ ទាក់ទងទៅនឹងជំនួយសង្គមរាជ រដ្ឋាភិបាលកម្ពុជាបានអនុវត្តកម្មវិធីជាច្រើន ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ និងប្រជាពលរដ្ឋងាយរងគ្រោះដែលរួមមាន៖ ការអភិវឌ្ឍន៍ធនធានមនុស្ស (កម្មវិធីផ្តល់អាហារបំប៉ននៅតាមសាលារៀន ការលើកកម្ពស់ អាហារូបត្ថម្ភសម្រាប់ស្ត្រីនិងកុមារ និងកម្មវិធីអាហារូបករណ៍) ការឆ្លើយតបនឹងគ្រោះអាសន្ន ជំនួយសុខភាពសង្គម សុខុមាលភាពសម្រាប់មនុស្សចាស់និងជនពិការ និងការអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជា ជីវៈ(TVET)។ ទោះជាយ៉ាងណាការចំណាយលើផ្នែកជំនួយសង្គមផ្តោតសំខាន់លើការអភិវឌ្ឍធនធានមនុស្ស និងការឆ្លើយតបនឹងគ្រោះអាសន្ន ហើយកម្មវិធីជំនួយសង្គមនេះក៏ប្រឈមនូវបញ្ហាមួយចំនួនផ្សេងទៀតដូចជា៖ ការសម្របសម្រួលមិនល្អរវាងជំនួយមនុស្សធម៌ និងប្រព័ន្ធជំនួយសង្គម ដើម្បីកំណត់អត្តសញ្ញាណក្រុមជនងាយរងគ្រោះ មិនមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ឡើយលើការផ្តល់អាហារូបត្ថម្ភទៅដល់ស្ត្រី និងកុមារ ការអនុវត្តកម្មវិធីអាហារូបករណ៍និងកម្មវិធីផ្តល់អាហារបំប៉ននៅតាមសាលារៀននូវមានលក្ខណៈចង្អៀត និងយុវជនដែលបោះបង់ការសិក្សាទទួលបានការអប់រំកម្រិតទាបដែលពិបាកដល់ការទទួលនូវការបណ្តុះបណ្តាលវិជ្ជាជីវៈ។

ចំពោះការធានារ៉ាប់រងសង្គមរាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគម្រោងធំៗចំនួន៣ រួមមានគម្រោងប្រាក់សោធននិវត្តន៍ ការធានារ៉ាប់រងសុខភាព និងគម្រោងគ្រោះថ្នាក់ការងារ។ សម្រាប់គម្រោងសោធននិវត្តន៍គឺបានអនុវត្តពេញលេញសម្រាប់មន្ត្រីសាធារណៈ ប៉ុន្តែរាជរដ្ឋាភិបាលបានប្តេជ្ញាថានឹងអនុវត្ត

គម្រោងនេះចំពោះផ្នែកឯកជន ក្នុងឆ្នាំ២០១៩។ ខណៈដែលគម្រោងធានារ៉ាប់រងសុខភាពត្រូវបានអនុវត្តបានមួយផ្នែកសម្រាប់និយោជិតឯកជន គម្រោងនេះអនុវត្តបានទាំងអស់សម្រាប់មន្ត្រីរាជការ។ សម្រាប់គម្រោងគ្រោះថ្នាក់ការងារ នឹងត្រូវបានអនុវត្តទាំងស្រុងសម្រាប់ទាំងបុគ្គលិកឯកជននិងសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយកម្មវិធីធានារ៉ាប់រងសង្គមត្រូវបានអនុវត្តក្រោមក្រសួងផ្សេងៗគ្នា បាននាំឱ្យមានភាពមិនស៊ីចង្វាក់ និងចំណាយមិនមានប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធី និងនាំមកនូវការអាក់អន់ចិត្តក្នុងចំណោមមន្ត្រីរាជការ។ លើសពីនេះទៅទៀតការចំណាយភាគច្រើនសម្រាប់មន្ត្រីសាធារណៈ ដែលចូលនិវត្តន៍ភាគច្រើនគឺពឹងទៅលើការបង់ពន្ធដែលមិនមែនជាវិភាគទានរួមចំណែកពីសាម៉ីជនដែលអាចមានហានិភ័យចំណាយ ដល់រាជរដ្ឋាភិបាលនាពេលអនាគត។

បន្ថែមលើលពីនេះទៅទៀត ក្នុងចំណោម ០៤ ប្រទេសខាងលើ ការចំណាយរបស់កម្ពុជាទៅលើវិស័យសុខាភិបាលជាចំណែកផ.ស.ស មានចំនួនតិចជាងគេពោលគឺតិចជាងប្រទេសជប៉ុន បារាំង និងថៃ ជាមួយគ្នានេះដែរប្រទេសបារាំងបាននាំមុខគេក្នុងការចំណាយកម្មវិធីគាំពារសង្គម រហូតដល់ទៅ៣,៤% នៃផ.ស.ស ជាមធ្យម ខណៈដែលប្រទេសជប៉ុន ២,៥% និងថៃ០,២%នៃផ.ស.ស ជាមធ្យម។

ម្យ៉ាងវិញទៀតបើប្រៀបធៀបទៅនឹងប្រទេសដទៃទៀតដែលទាក់ទងទៅនឹងកម្មវិធី / គោលនយោបាយគាំពារសង្គមប្រទេសកម្ពុជាក៏បានអនុវត្តដូចប្រទេសថៃ ជប៉ុន និងប្រទេសបារាំងផងដែរ។ ប្រទេសកម្ពុជាក៏បានអនុវត្តកម្មវិធីប្រាក់សោធននិវត្តន៍សម្រាប់ជនចាស់ជរា ពិការភាព ឧត្តរជីវី ជំងឺនិងមាតុភាព គ្រោះថ្នាក់ការងារ និងប្រាក់ឧបត្ថម្ភគ្រួសារ។ ប៉ុន្តែវាគួរអោយកត់សំគាល់ថាប្រទេសកម្ពុជាមិនបានអនុវត្តគម្រោងធានារ៉ាប់រងភាពអត់ការងារធ្វើ ដូចប្រទេសបីផ្សេងទៀត ដែលអាចពិចារណាជាគោលនយោបាយនាពេលអនាគត។

នៅចុងបញ្ចប់ដើម្បីធានាបាននូវនិរន្តរភាពនៃកម្មវិធីនេះត្រូវមានការរួមវិភាគទានពីតួអង្គសំខាន់ៗចំនួន ៤ គឺជានិយោជក និយោជិត រដ្ឋាភិបាល និងអ្នកប្រកបមុខរបរផ្ទាល់ខ្លួន ខណៈដែលគោលនយោបាយរបស់កម្ពុជាទាក់ទងនឹងរបបសន្តិសុខសង្គមមិនទាន់បានរំលេចពីការចូលរួមពីអ្នកប្រកបមុខរបរផ្ទាល់ខ្លួននោះទេ។

## ឯកសារយោង

1. WB. (2018). *The World Bank In Cambodia* [Online]. WB. Available at: https://www.worldbank.org/en/country/cambodia/overview [Accessed 25 Dec 2018].
2. ADB. (2018). *Poverty in Cambodia* [Online]. ADB. Available at: https://www.adb.org/countries/cambodia/poverty [Accessed 25 Dec 2018].

3. RGC, (2017). *Social Policy Protection Framework 2016-2025*. PP: RGC.
4. ILO, (2012). *Social Protection Expenditure and Performance Review* ILO.
5. OECD, (2017). *Social Protection System Review of Cambodia.* Paris: OECD, Available at: https://www.oecd-ilibrary.org/docserver/9789264282285-en.pdf?expires=1545723974&id=id&accname=guest&checksum=BE32BF882D7F5BD84DA470B4D7644FF0.
6. MOH, (2017). *Progress Report in 2017 and Plan in 2018.* MOH, Available at: http://moh.gov.kh/content/uploads/2017/05/MOH-Report-Kh-V6.pdf.
7. RGC, (2018). *The Statement of Budgeg Law 2019*. PP: NA.
8. National Security Fund. (2014). *The Contribution for Health and Occupational Riks Payment* [Online]. NSF. Available at: http://www.nssf.gov.kh/default/ [Accessed 29 November 2018].
9. NSF, (2018). *The Report for 10 Years Achievement (2008-2017) and Vision for 2018* RGC.
10. USAID, (2018). *Cambodia: Nutrition Profile* USAID, Available at: https://www.usaid.gov/sites/default/files/documents/1864/Cambodia-Nutrition-Profile-Mar2018-508.pdf.
11. Government, R., (2016-2025). *National Social Protection Policy Framework*. Available at: http://inndec.com/library/docs/SPPF%20English%20-%20Final%20Ver.pdf.
12. Hui, K. (2016). *Social Health Protection* [Online]. GIZ. Available at: http://giz-cambodia.com/wordpress/wp-content/uploads/FactSheet-Reforming-Cambodia%E2%80%99s-Social-Protection-Framework.pdf.
13. International Social Security Association, (2018). *Social Security Programs Throughout the World: Europe, 2018.* ISSA.
14. United Nations Statistics Division (2018). Table 3.1 Government final consumption expenditure by function at current prices. *In:* UNdata (ed.) *National Accounts Official Country Data.*